|---|---|---|---|---|
| ១៤០៣ | ទូ សុភាព | ស | ១២-០២-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤០៤ | យ៉ាន ចណ្ណានី | ស | ០២-០៦-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤០៥ | រស់ សៅណារុន | ប | ១៣-០៦-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤០៦ | សុខ ឌី | ប | ០៥-០១-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤០៧ | សេន ភក្តី | ប | ១៨-០៤-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤០៨ | ឡុង ឌុន្ធី | ប | ០៦-០៩-៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤០៩ | ឡេង ម៉ាឌីរ៉េ | ប | ០៥-០៨-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១០ | ឡុង ស្រស់ | ប | ១៥-០៦-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១១ | សារឿន អង្គារិទ្ធ | ប | ០១-០១-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១២ | ញ៉ាញ់ សារឿន | ប | ៣០-០៣-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១៣ | ញួង ចានិន | ប | ០១-១០-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១៤ | ប៉ុម សារឿន | ប | ២៥-១០-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១៥ | មាស សុផានី | ស | ២៧-០៩-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១៦ | លន់ ម៉ារ៉ាឌី | ប | ២៩-០២-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១៧ | គ្រេន សុភក្តិ | ប | ២៥-០៧-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១៨ | សាយ ច័ន្ទសីហា | ស | ២២-០៨-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤១៩ | ហេង គុងហ្វ | ប | ២២-០៩-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២០ | ឡឹក នារី | ស | ០៤-០៥-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២១ | នាក់ ដែត | ស | ២០-០៥-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២២ | ស ចាន់ណារី | ស | ២០-១០-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២៣ | ម៉ិច គន្ធា | ស | ០៣-០៣-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២៤ | នេត ពៅ | ប | ១៨-១០-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២៥ | មិន ចាន់ថាវី | ស | ២០-១០-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២៦ | ឈឹម ឌុត្ថា | ស | ១០-០២-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២៧ | ហៀង សុបិន្ត | ប | ១០-០៨-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២៨ | ស ជួបនាសនា | ប | ០១-០៧-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤២៩ | ឡៀង សំណាង | ប | ២៨-១២-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣០ | អ៊ិន ភារី | ប | ១០-០៨-៨៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣១ | ពេញ យ៉ា | ប | ០៧-០៥-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣២ | ភាង ដែនពិសិដ្ឋ | ប | ០១-១០-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣៣ | ហែម ប៊ុនធិច | ប | ១២-១២-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣៤ | ខ្វាន់ សុភក្ត្រនាថ | ស | ១០-០៧-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |

| | | | | |
|---|---|---|---|---|
| ១៤៣៥ | យ៉េម សុគុណា | ស | ១២.១២.៨១ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣៦ | លី ប៊ុណ្ណារ៉ា | ប | ២៨.០៤.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣៧ | ជី សាមឌី | ប | ១៨.០៦.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣៨ | នៃ ឌុឡៅ | ប | ២៥.០៧.៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៣៩ | ឡៅ សុផារី | ប | ១៥.០៣.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤០ | យ៉ន សុខលីន | ស | ១០.០២.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤១ | សែត ស្រីពៅ | ស | ១០.០៤.៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤២ | ម៉េង សារ៉ាត់ | ប | ១០.១០.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤៣ | អឹម វណ្ណឌី | ស | ០៩.០៩.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤៤ | ញឹប ចំរើន | ប | ២៥.០២.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤៥ | យ៉េម សារាយ | ប | ០៧.០៦.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤៦ | តុប ចាន់ថេន | ប | ១២.១២.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤៧ | ឡាក់ ថៃសុវណ្ណា | ប | ១៨.០៦.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤៨ | ជៀស ឌីនីន | ប | ២០.០១៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៤៩ | ប៉ៃ ពុទ្ធារិទ្ធិ | ស | ២៧.០៨.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥០ | ស៊ាង រ៉ៃ | ប | ២០.០២.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥១ | គឹម ពុធ | ប | ០៦.០៦.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥២ | ឡេង សារេត | ប | ១២.០៨.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥៣ | អ៊ី មិថុត្រា | ប | ០២.០១.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥៤ | ឡាង តារិត | ប | ១០.១១.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥៥ | អ៊ិន មិថ្ថិកា | ប | ០៤.១១.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥៦ | សំ ចន្ធូ | ស | ១០.០១.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥៧ | យឹម ដានី | ប | ១៦.០៣.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥៨ | ហាំង សំខាន់ | ប | ០៥.០២.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៥៩ | ម៉ឿង សុម៉ាលី | ប | ១០.១១.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦០ | គឹម សុធី | ស | ១៩.០៩.៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦១ | សុង លីដា | ស | ១៤.០២.៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦២ | ទឹម មិនា | ស | ១០.០៥.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦៣ | សុខ សុខុម | ប | ១៨.០៨.៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦៤ | ប៉ែន សៅរ៉ា | ប | ០៩.០៩.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦៥ | ជើម ពុទ្ធី | ប | ១២.០៧.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦៦ | គី វណ្ណារៈ | ប | ០៦.០២.៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |

| | | | | |
|---|---|---|---|---|
| ១៤៦៧ | ឃី សុចាន់ណារី | ស | ០២.០២.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦៨ | ធិត ពិសិដ្ឋ | ប | ០៧.០៦.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៦៩ | សេង ភុម្ភៈ | ប | ២០.០២.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧០ | ចោង ពៅ | ប | ០១.១២.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧១ | ស៊ីម ប្រុស | ប | ១០.០២.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧២ | ម៉ៅ ចរិយា | ស | ០៣.០៦.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧៣ | ខ៉ាន់ សាខុន | ប | ០៧.០៧.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧៤ | អេង ចិន្តា | ស | ០៩.០៤.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧៥ | ចៀន ចាន់ណារ៉ាត | ប | ២១.១០.៨៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧៦ | ជី ធឿន | ប | ១០.១១.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧៧ | សេង មករា | ប | ០៩.១០.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧៨ | សុខ ផន | ប | ១៣.០៧.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៧៩ | យ៉ាន់ ឡឿន | ប | ២៤.០៧.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨០ | ឃុន ធី | ប | ១៥.០២.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨១ | ហង់ នុំ | ប | ០៥.០៣.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨២ | អ៊ីវ និត | ប | ០៨.០៦.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨៣ | ម៉ែន ដារ៉ារិទ្ធ | ប | ១២.០៨.៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨៤ | ហែម ចាន់ដារិទ្ធ | ប | ១៤.០៥.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨៥ | អ៊ឹម សារី | ប | ០៨.១០.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨៦ | សែម រិទ្ធី | ប | ២០.០១.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨៧ | គាត ណុន | ប | ០១.១០.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨៨ | ហេង សារឿន | ប | ០២.០៤.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៨៩ | មុត ឆាសនា | ប | ១៣.០៤.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩០ | ណុប យឿន | ស | ២៥.០៣.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩១ | គុណា ចាន់ដារ៉ា | ប | ០៧.០២.៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩២ | ឡុង គីមសឿន | ស | ០១.០១.៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩៣ | ម៉ុំ ពៅ | ប | ១២.០៥.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩៤ | សុ សម្បត្តិ | ប | ០៥.០៩.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩៥ | ស៊ុន សុធាវី | ស | ១១.១១.៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩៦ | ស ណុន | ប | ២៣.០៦.៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩៧ | តែម លក្ខិណា | ស | ១៨.០៤.៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៤៩៨ | នីង សានចន្ថាច | ស | ៣០.០៥.៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |

| | | | | |
|---|---|---|---|---|
| ១៤៩៩ | ស៊ុន សុភាព | ស | ២៥-០៩-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០០ | ច័ន្ទ សំបូរ | ប | ១៥-០៥-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០១ | សៅ ឡឿន | ប | ១០-១៨-៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០២ | អ៊ឹម សុផន | ប | ១៥-០២-៨៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០៣ | សៀ សុភក្តិ | ប | ០១-០៣-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០៤ | ម៉ុល មរកត | ប | ១៦-០៤-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០៥ | សៅ សារេត | ប | ០៣-០៩-៦៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០៦ | ម៉ុន ពុទ្ធី | ប | ០១-០១-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០៧ | យ៉ែម សារ៉ាត់ | ប | ១០-១០-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០៨ | ស៊ុន ច័ន្ទសុភារ័ត្ន | ប | ២៥-០៥-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥០៩ | អ៊ិន គុណា | ប | ១២-០៩-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១០ | កែវ សុផល | ប | ១២-០២-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១១ | ស៊ិន សុផល | ប | ០៩-០៧-៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១២ | នួច ពុំ | ប | ០១-០១-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១៣ | ម៉ុស ថន | ប | ១៥-០៥-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១៤ | លន់ ចេនា | ប | ២៨-១០-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១៥ | ឈិត សុតា | ប | ៣០-០១-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១៦ | រ៉ែន ផល្លី | ប | ២០-១០-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១៧ | នួន សុវណ្ណា | ប | ០៣-០៩-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១៨ | ម៉េង នាយប្រិមប្រិយ | ស | ១០-១០-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥១៩ | យឹម ឆានី | ប | ២១-០៨-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២០ | យន រឿន | ប | ១១-០៩-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២១ | ជុំ ចាន់ណា | ប | ០៥-០៣-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២២ | សឺវ ហ៊ីហុនម៉ុណ្ណាលីឌ័រ | ប | ០២-០៧-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២៣ | អ៊ីវ សារី | ប | ០១-០១-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២៤ | ម៉ិច ហេង | ប | ១៨-០៦-៨៩ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២៥ | ចេក សុខុម | ស | ៣០-១០-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២៦ | តោគ តិរិទ្ធ | ប | ២៨-០១-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២៧ | ស៊ិប ឡូក | ប | ០៣-០៤-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២៨ | សម ច័ន្ទផល | ប | ១០-០៧-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥២៩ | អន សំអុល | ប | ០៥-០៥-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣០ | ជ័យ ខេមរា | ប | ១២-១១-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |

| | | | | |
|---|---|---|---|---|
| ១៥៣១ | ឡឹង សោភ័ណ្ឌា | ស | ២៩-០៩-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣២ | ឈាន ជីន | ប | ១៣-០២-៨៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣៣ | ជា ឡា | ប | ០៣-០១-៨២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣៤ | អឹម ធូ | ប | ១២-០៦-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣៥ | ឆេង ទុំ | ប | ០៣-០៨-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣៦ | ហង់ សំហឿន | ប | ១៦-០៦-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣៧ | ហេង ចំរើន | ប | ១៦-០៦-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣៨ | ហែម សិរីវឌ្ឍនា | ប | ១២-០៧-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៣៩ | អេង សុខអ៊ាម | ប | ០៧-១០-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤០ | សឿន ដារ៉ា | ប | ១៤-០៤-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤១ | ឡឹក ចំណាប់ | ប | ២០-០៧-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤២ | រិន សារិទ្ធ | ប | ១៣-០៤-៨៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤៣ | អឿន សេងអ៊ាម | ប | ២៤-០៤-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤៤ | បេង សុភ័ក្ត្រ | ប | ០៩-១១-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤៥ | ជួប ទិសាល | ប | ០៥-០៩-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤៦ | អឿ គន្ធា | ស | ០១-០៣-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤៧ | ឌឿង សុភ័ក្ត្រ | ស | ៣១-១២-៨៩ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤៨ | សាន់ សោម៉ា | ស | ០១-០២-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៤៩ | សៀ រក្សា | ប | ១២-១២-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥០ | នាង ចន្ទី | ស | ១៧-០១-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥១ | ផន ចំរើន | ប | ០២-០៤-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥២ | ឯម សុផាណារិទ្ធិ | ប | ០១-០១-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥៣ | ឡាយ សេងហួត | ប | ០៧-០៤-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥៤ | សេង សុខហាន | ប | ១១-១២-៨៤ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥៥ | អ៊ុង ច័ន្ទសុភណ្ឌារិទ្ធ | ប | ១៤-០៨-៨៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥៦ | មុំ ប៊ុនធឿន | ប | ០៦-០២-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥៧ | កន កុសល | ប | ០៧-០៧-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥៨ | ស៊ឹង សីហា | ប | ១៧-០៨-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៥៩ | អ៊ឹម មនោរម្យ | ប | ១៥-១០-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៦០ | សុត ស្រមុំ | ស | ៣០-០៤-៨៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៦១ | អ៊ំ ឧត្តី | ប | ០១-១០-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៦២ | ខាន់ សុខនាង | ប | ២៥-០៧-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |

| | | | | |
|---|---|---|---|---|
| ១៥៦៣ | **ម៉ែត ម៉ាត** | ប | ១៨-១១-៨៦ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៦៤ | **យស់ ពុទ្ធារិទ្ធិ** | ប | ០៥-១០-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៦៥ | **ប៊ិត សុម៉ានី** | ប | ០៣-០៤-៨៧ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៦៦ | **ម៉ៅ សុត័ណ្ណា** | ប | ០៨-០៥-៨៣ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |
| ១៥៦៧ | **ផុក ធានី** | ប | ២០-០៤-៨៥ | គ្រូបង្រៀនកម្រិតមូលដ្ឋាន ថ្នាក់លេខ១៤ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>*កន្លែងទទួល*</u>

*- ក្រសួងព្រះបរមរាជវាំង*
*- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*- អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*- អគ្គលេខាធិការរាជរដ្ឋាភិបាល*
*- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*- ដូចមាត្រា ២*
*- រាជកិច្ច*
*- ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧១៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន

- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ-
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** ត្រូវបានតាំងស៊ប់មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន ទៅក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដូចមានរាយនាមខាងក្រោម ៖

| ល.រ | នាម និងគោត្តនាម | ភេទ | ថ្ងៃ-ខែ-ឆ្នាំកំណើត | ឋានន្តរស័ក្តិ និងថ្នាក់ |
|---|---|---|---|---|
| **ក្រសួងព័ត៌មាន** | | | | |
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១០ តទៅ | | | | |
| ១ | **ឈុន ម៉ារ៉ាឌី** | ស | ០២-០៥-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២ | **សូ សម្ផស្ស** | ស | ០៩-០៦-១៩៨៨ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣ | **ទេព ចរិយា** | ស | ១០-០៨-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤ | **ពួន ម៉ូលី** | ស | ០៣-១១-១៩៧៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៥ | **ឥម សុផារិទ្ធ** | ស | ១៨-០៤-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៦ | **នាង សារុំ** | ប | ៣០-០១-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៧ | **ទូ សុវណ្ណារ័ត្ន** | ស | ០៣-០៥-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៨ | **ហ៊ីន ហៀងផេង** | ប | ០៣-០៥-១៩៨០ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៩ | **ខេមរិទ្ធ ដានីន** | ស | ២៧-១១-១៩៨២ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១០ | **ម៉ែន ចន្ទ្រានៈ** | ស | ២២-០៧-១៩៨៨ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១១ | **សេង ទាន់** | ប | ១០-០២-១៩៨០ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១២ | **ហុក សុខរិន** | ប | ១០-០១- ១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៣ | **អ៊ិន ហ្សានីន** | ស | ២០-១១-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៤ | **ម៉េន គីមហ៊ាន់** | ស | ១០-០៣-១៩៨១ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៥ | **សំ ចំរើន** | ប | ២៤-០៧-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៦ | **គុណ ចំណូល** | ប | ១៧-១១-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៧ | **ផន ទាសនា** | ស | ១៨-០៧-១៩៨៨ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ១៨ | **សំ កុសល** | ប | ២៧-០៧-១៩៨០ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |

| ក្រសួងបរិស្ថាន | | | | |
|---|---|---|---|---|
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ តទៅ | | | | |
| ១ | **ធី ច័ន្ទតារា** | ប | ០៩-០៤-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ២ | **រ៉ែត ស្រីលី** | ស | ០៧-០៦-១៩៨១ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៣ | **ហួត នីតា** | ប | ០៥-១០-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៤ | **ស៊ឹម ម៉ិនហេន** | ប | ១៤-០៩-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| តាំងស៊ប់គិតចាប់ពីថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១០ តទៅ | | | | |
| ៥ | **អេង ចាន់ណា** | ស | ១០-០៩-១៩៨៤ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៦ | **ជុន ស៊ុំខុន** | ប | ០៧-០២-១៩៧៩ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៧ | **អ៊ុយ ឌីម** | ប | ០២-០៦-១៩៨៥ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៨ | **អ៊ិន សៅ** | ប | ១០-០៩-១៩៨៧ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |
| ៩ | **យស់ ទិមុល** | ស | ០១-១០-១៩៨១ | មន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១៤ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

# សម្រេច

**មាត្រា ១ :** ត្រូវបានដាក់មន្ត្រីរាជការឋានន្តរស័ក្តិរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | មុខតំណែង | ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃខែឆ្នាំ ចូលនិវត្តន៍ |
|---|---|---|---|---|---|---|
| **ក្រសួងព័ត៌មាន** | | | | | | |
| ១ | **ឌី សុខណាត** | ប | ១១-០១-១៩៤៩ | អគ្គនាយករង | ក.២.១ | ០១-០១-២០១០ |
| ២ | **ស៊ូ នី** | ប | ០៩-១០-១៩៥០ | ប្រធាននាយកដ្ឋាន | ក.២.១ | ០១-១១-២០១០ |
| ៣ | **តាក់ លីហុក** | ប | ០៣-០២-១៩៥០ | អគ្គនាយករង | ក.២.២ | ០១-០៣-២០១០ |
| ៤ | **ចាន់ សាវ៉ាត** | ប | ២៨-០៩-១៩៥០ | ប្រធាននាយកដ្ឋាន | ក.២.២ | ០១-១០-២០១០ |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | | | | |
| ១ | **ផាត់ លេង** | ប | ០៥-០៩-១៩៥០ | អគ្គាធិការរង | ក.២.៥ | ០១-១០-២០១០ |
| **ក្រសួងបរិស្ថាន** | | | | | | |
| ១ | **ទង់ ឆេងគង់** | ប | ១០-១០-១៩៥០ | អគ្គាធិការរង | ក.២.៦ | ០១-១១-២០១០ |
| **ក្រសួងទេសចរណ៍** | | | | | | |
| ១ | **អ៊ឹក សុខា** | ប | ១៤-០៦-១៩៥០ | ប្រធាននាយកដ្ឋាន | ក.២.៦ | ០១-០៧-២០១០ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | | | | | | |
| ១ | **ញឹម ម៉ាន់ច័ន្ទកន** | ស | ១០-១១-១៩៥១ | អគ្គាធិការរង | ក.២.១ | ០១-១២-២០១១ |
| ២ | **វ៉ែត សុខា** | ប | ១០-០៨-១៩៥១ | ប្រធាននាយកដ្ឋាន | ក.២.២ | ០១-០៩-២០១១ |
| ៣ | **អ៊ូ អេង** | ប | ០៣-០៩-១៩៥១ | អគ្គនាយក | ក.២.៦ | ០១-១០-២០១១ |
| ៤ | **គីម អមរា** | ប | ០១-០១-១៩៥១ | អគ្គនាយករង | ក.២.៦ | ០១-០២-២០១១ |
| ៥ | **អ៊ីម កុច** | ប | ១០-០៣-១៩៥១ | នាយកវិទ្យាស្ថាន ថ្នាក់ស្មើអគ្គនាយក | ក.២.៧ | ០១-០៤-២០១១ |
| ៦ | **ចាន់ វ៉ែតសុផា** | ប | ១៨-០៥-១៩៥១ | អគ្គនាយករង | ក.២.៨ | ០១-០៦-២០១១ |
| ៧ | **ប៉ក់ ផាឌិន** | ប | ២០-០៥-១៩៥១ | អគ្គនាយក | ក.២.១០ | ០១-០៦-២០១១ |
| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | | | | |
| ១ | **ម៉ែន ឌុយ** | ប | ២១-០១-១៩៥១ | ប្រធានមន្ទីរ | ក.២.៤ | ០១-០២-២០១១ |
| ២ | **អៀង ស្រេង** | ប | ១៣-០៧-១៩៥១ | ប្រធាននាយកដ្ឋាន | ក.២.៧ | ០១-០៨-២០១១ |
| **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** | | | | | | |
| ១ | **ហូ ភាជិប** | ប | ១៨-០៧-១៩៥១ | អគ្គនាយករង | ក.២.២ | ០១-០៨-២០១១ |
| **ក្រសួងពាណិជ្ជកម្ម** | | | | | | |
| ១ | **ចិន យ៉ាណ្ណា** | ប | ០១-០៨-១៩៥១ | មន្ត្រី | ក.២.៦ | ០១-០៨-២០១១ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួង

បរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៥ .សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជា ជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជាជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ដូចមានសមាសភាពខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **អ៊ឹម ឈុនលឹម** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- ឯកឧត្តម | **ម៉ុក ម៉ារ៉េត** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| ៣- ឯកឧត្តម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឯកឧត្តម | **ស្បោង សារ៉ាត់** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | សមាជិក |

៥- ឯកឧត្តម **ហាស់ សារ៉េត** អភិបាលនៃគណៈអភិបាលខេត្តកែប សមាជិក
៦- ឯកឧត្តម **ខូយ ឃុនហួរ** អភិបាលនៃគណៈអភិបាលខេត្តកំពត សមាជិក
៧- ឯកឧត្តម **ប៊ុន លើត** អភិបាលនៃគណៈអភិបាលខេត្តកោះកុង សមាជិក
៨- ឯកឧត្តម **និត ចន្ថា** អគ្គនាយកទេសចរណ៍នៃក្រសួងទេសចរណ៍ សមាជិក
៩- ឯកឧត្តម **ជា ម៉ូរ៉ា** អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងទេសចរណ៍ សមាជិក
១០- លោក **វ៉ាន់ មុនីនាថ** អគ្គនាយករងបច្ចេកទេសនៃក្រសួងបរិស្ថាន សមាជិក
១១- លោក **ណោប សាមុត** អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ សមាជិក
១២- លោក **ម៉ែន សុផល** ប្រធាននាយកដ្ឋាននគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
១៣- លោកស្រី **ចៅ ស៊ុន កិរិយា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌនៃអាជ្ញាធរអប្សរា សមាជិក។

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សហការជាមួយក្រុមប្រឹក្សាភិបាលក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកដើម្បីដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជាជាសមាជិកក្លឹប
- លើកវិធានការទប់ស្កាត់ជាបន្ទាន់រាល់សកម្មភាពដែលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិតំបន់ឆ្នេរ
- ធានាការរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ និងភាពស្រស់ស្អាតនៅតាមតំបន់ឆ្នេរ
- ជំរុញការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវ
- រៀបចំឯកសារពាក់ព័ន្ធឆ្លងការសម្រេច ពីរាជរដ្ឋាភិបាលមុននឹងដាក់ជូនក្រុមប្រឹក្សាភិបាលក្លឹប
- សហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍក្នុងវិស័យពាក់ព័ន្ធដើម្បីបំពេញកិច្ចការខាងលើ
- ធ្វើរបាយការណ៍លម្អិតអំពីលទ្ធផលការងារដែលបានអនុវត្តជូនរាជរដ្ឋាភិបាល។

**ប្រការ ៣ :** គណៈកម្មការអន្តរក្រសួង មានក្រុមលេខាធិការ ជាជំនួយការដែលមានសមាសភាពដូចខាងក្រោម ៖

១- លោក **ណោប សាមុត** អគ្គនាយករងទេសចរណ៍នៃក្រសួងទេសចរណ៍ ប្រធាន
២- លោក **វ៉ាន់ មុនីនាថ** អគ្គនាយករងបច្ចេកទេសនៃក្រសួងបរិស្ថាន អនុប្រធាន
៣- លោក **ម៉ែន សុផល** ប្រធាននាយកដ្ឋាននគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
៤- លោកស្រី **ចៅ ស៊ុន កិរិយា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌនៃអាជ្ញាធរអប្សរា សមាជិក
៥- លោក **សុខ សុគុណា** ប្រធាននាយកដ្ឋានផែនការ អភិវឌ្ឍទេសចរណ៍នៃក្រសួងទេសចរណ៍ សមាជិក
៦- លោក **ផុក សុខុម** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាននៃក្រសួងទេសចរណ៍ សមាជិក
៧- លោក **សូ ចិសុទ្ធី** ប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយនៃក្រសួងទេសចរណ៍ សមាជិក
៨- លោក **កែវ គួច** ប្រធាននាយកដ្ឋានអភិវឌ្ឍទេសចរណ៍វប្បធម៌នៃក្រសួងទេសចរណ៍ សមាជិក។

**ប្រការ ៤** : ក្រុមលេខាធិការ មានភារកិច្ចដូចខាងក្រោម ៖

- ជាជំនួយការដល់គណៈកម្មការអន្តរក្រសួងក្នុងការបំពេញតួនាទី និងភារកិច្ចដូចចែងក្នុងប្រការ ២
- ទទួលបន្ទុកការងាររដ្ឋបាលទូទៅរបស់គណៈកម្មការអន្តរក្រសួង រួមទាំងរបាយការណ៍បូកសរុបរាល់ការងារនីមួយៗដែលអនុវត្តបាន
- ទាក់ទង និងប្រមូលព័ត៌មានឯកសារពីក្រសួងស្ថាប័នរដ្ឋ និងឯកជនដែលពាក់ព័ន្ធ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការបំពេញការងាររបស់គណៈកម្មការអន្តរក្រសួង
- សម្របសម្រួលការងារជាមួយក្រុមប្រឹក្សាភិបាលក្លឹប។

**ប្រការ ៥** : គណៈកម្មការអន្តរក្រសួង មានសិទ្ធិបង្កើតក្រុមការងារថ្នាក់ខេត្តនៅតាមបណ្តាខេត្តឆ្នេរទាំងបួនដើម្បីជាជំនួយការក្នុងការបំពេញភារកិច្ចឲ្យមានប្រសិទ្ធភាព។

ក្រុមការងារថ្នាក់ខេត្ត មានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យ និងតាមដានសណ្តាប់ធ្នាប់ របៀបរៀបរយនៅតាមតំបន់ឆ្នេរ
- ជំរុញការបញ្ជ្រាបការយល់ដឹងអំពីបរិស្ថានដល់អាជីវករ និងប្រជាពលរដ្ឋមូលដ្ឋាន
- ណែនាំដល់អាជីវករអំពីផលប៉ះពាល់ដល់តំបន់ឆ្នេរដែលបណ្តាលមកពីកាកសំណល់រឹង និងរាវ
- ធ្វើរបាយការណ៍ជាប្រចាំអំពីសកម្មភាព និងស្ថានភាពនៅតាមតំបន់ឆ្នេរដល់ក្រុមលេខាធិការ។

**ប្រការ ៦** : សមាជិកគណៈកម្មការអន្តរក្រសួង ក្រុមការងារថ្នាក់ខេត្ត ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ ៧** : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍។

**ប្រការ ៨** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ អភិបាលនៃគណៈអភិបាលខេត្តកែប អភិបាលនៃគណៈអភិបាលខេត្តកំពត អភិបាលនៃគណៈអភិបាលខេត្តកោះកុង ប្រធានអាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល:***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៩*
- *រាជកិច្ច ✓*
- *ឯកសារ-កាលប្បវត្តិ*



/ ៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៥៧៦ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

## ប្រកាស
## ស្តីពី
## ការរាយការណ៍អំពីទំនិញនាពេលចូលក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

ទំនិញ បរិក្ខារ និងមធ្យោបាយដឹកជញ្ជូនទាំងអស់ ដែលត្រូវបាននាំចូលក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា ត្រូវដឹកជញ្ជូនដោយគ្មានបង្អែបង្អង់ តាមតម្រាយផ្លូវស្របច្បាប់ ទៅកាន់ការិយាល័យគយដែលជិតជាងគេបំផុត ឬទីកន្លែងណាមួយផ្សេងទៀតដែល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ត្រូវបានកំណត់ដោយរដ្ឋបាលគយ ហើយត្រូវរាយការណ៍ជូនរដ្ឋបាលគយ តាមការតម្រូវដែលត្រូវបានកំណត់ដោយអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។ លើកលែងតែបញ្ញត្តិដូចមានចែងក្នុងប្រការ ៦ ខាងក្រោមទំនិញទាំងឡាយត្រូវបានរាយការណ៍ជូនរដ្ឋបាលគយ ក្នុងពេលម៉ោងធ្វើការនៃការិយា-ល័យគយ ។

ស្ថានភាពដើមនៃទំនិញ និងកញ្ចប់ទាំងឡាយត្រូវរក្សាទុកតាមសភាពដើមក្នុងដំណើរការនេះ ហើយ សៀល ឬត្រាភ្ជិតនានាត្រូវរក្សាសភាពដើមមិនប៉ះពាល់ ។

**ប្រការ ២ .-**

ការតម្រូវឱ្យរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយ ត្រូវអនុវត្តដោយស្មើភាពគ្នាដោយមិនប្រកាន់ចំពោះប្រទេសដើមកំណើតទំនិញឬប្រទេសដែលទំនិញត្រូវបាននាំចេញឡើយ ។

**ប្រការ ៣ .-**

ការរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយ ត្រូវធ្វើឡើងតាមរយៈប្រតិវេទន៍គយបំពេញ នៅពេលដែលទំនិញចូលមកក្នុងដែនគយ ។

**ប្រការ ៤ .-**

ទំនិញទាំងឡាយត្រូវបានរាយការណ៍ជូនរដ្ឋបាលគយ ដោយប្រតិវេទន៍គយជាលាយលក្ខណ៍អក្សរ ឬដោយការប្រកាសផ្ទាល់មាត់ តាមការកំណត់របស់អគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥ .-**

បុគ្គលទាំងឡាយដែលរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយ ត្រូវទទួលខុសត្រូវនូវភាពត្រឹមត្រូវនៃការប្រកាសរបស់ខ្លួន ។

**ប្រការ ៦ .-**

ទំនិញទាំងឡាយត្រូវរាយការណ៍នៅតាមការិយាល័យគយមានសមត្ថកិច្ច ។

បុគ្គលទាំងឡាយ ដែលមានបំណងរាយការណ៍អំពីទំនិញរបស់ខ្លួន ជូនរដ្ឋបាលគយនៅទីកន្លែងផ្សេងក្រៅពីការិយាល័យគយ ត្រូវតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីរដ្ឋបាលគយ តាមបញ្ញត្តិនៃប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុញ្ញាតឱ្យបំពេញទម្រង់ការគយនៅក្រៅការិយាល័យគយ ។

អ្នកដឹកជញ្ជូនទំនិញត្រូវមានការអនុញ្ញាតពីរដ្ឋបាលគយនៅជាប់នឹងខ្លួន ក្នុងពេលដឹកជញ្ជូនទំនិញ ។

មន្ត្រីគយអាចអមមធ្យោបាយដឹកជញ្ជូន និងទំនិញ និងអាចត្រួតពិនិត្យទាំងមធ្យោបាយដឹកជញ្ជូន និងទំនិញទាំងនេះ នៅកន្លែងដែលត្រូវបើចេញ ។

បុគ្គលទាំងឡាយ ដែលមានបំណងរាយការណ៍ពីទំនិញជូនរដ្ឋបាលគយ នៅក្រៅពេលម៉ោងធ្វើការរបស់ការិយាល័យគយ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលគយ ។ រដ្ឋបាលគយអាចកំណត់បន្ទុកចំណាយលើសេវាទាំងនេះ ។

**ប្រការ ៧ .-**

បុគ្គលទាំងឡាយ ដែលទទួលខុសត្រូវក្នុងការរាយការណ៍អំពីទំនិញជូនរដ្ឋបាលគយតាមបញ្ញត្តិមាត្រា ១១ នៃច្បាប់ស្ដីពីគយត្រូវរៀបចំបង្ហាញនូវទំនិញ និងមធ្យោបាយដឹកជញ្ជូនសម្រាប់ការត្រួតពិនិត្យនាពេលមានការតម្រូវដោយគយ និងត្រូវឆ្លើយនូវការពិតលើសំណួរណាមួយ ដែលត្រូវបានសួរដោយមន្ត្រីគយ ។

**ប្រការ៨ .-**

ទំនិញទាំងឡាយដែលបានមកដល់តាមផ្លូវសមុទ្រ ឬផ្លូវទឹកផ្សេងទៀត ត្រូវកត់ត្រានៅលើនិវេទន៍ប័ណ្ណនាវា ឬបញ្ជីទំនិញទូទៅ ដែលត្រូវបានដាក់តាមនាវា ។

ឯកសារទាំងនេះត្រូវចុះហត្ថលេខាដោយនាវាបតី និងត្រូវមានចែងពីសេចក្ដីបរិយាយនៃមុខទំនិញ រាប់បញ្ចូលទាំង បរិមាណ ម៉ាកសញ្ញា ទម្ងន់សរុប (ទម្ងន់ទាំងសំបកវេចខ្ចប់) ប្រភេទទំនិញ ព្រមទាំងទីកន្លែងដែលទំនិញត្រូវបានផ្ទុកចូលនាវា ។

ទំនិញហាមឃាត់ទាំងឡាយត្រូវបានរាយការណ៍នៅក្នុងនិវេទន៍ប័ណ្ណ ដោយមានសេចក្ដីបរិយាយត្រឹមត្រូវតាមលក្ខណៈ និងប្រភេទ ។

ត្រូវបានហាមឃាត់ការរាយការណ៍ជាទំនិញតែមួយ នៅក្នុងនិវេទន៍ប័ណ្ណមួយចំពោះទំនិញដែលត្រូវបានវេចខ្ចប់ដោយឡែកពីគ្នាជាច្រើនមុខ ទោះបីទំនិញទាំងនោះជាផ្នែកនៃទំនិញដឹកជញ្ជូនរួមគ្នាក្ដី ។

**ប្រការ ៩ .-**

នាពេលមកដល់តំបន់ឆ្នេរនៃដែនគយ តាមការស្នើសុំរបស់មន្ត្រីគយ នាវាបតីត្រូវផ្ដល់ជាបន្ទាន់នូវ ៖

- ឯកសារច្បាប់ដើមនៃនិវេទន៍ប័ណ្ណ ជូនមន្ត្រីគយមានសមត្ថកិច្ច ដែលនឹងចុះទិដ្ឋាការចូល ដែលចែងថា : " **មិនមានការកែប្រែ NO AMENDMENT** "

- ឯកសារមួយច្បាប់នៃនិវេទន៍ប័ណ្ណ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតជូនមន្ត្រីគយ ។

**ប្រការ ១០ .-**

នាវាទាំងឡាយអាចចូលចត និងលើកទំនិញចេញបាន តែនៅតាមកំពង់ផែទាំងឡាយណាដែលមានការិយាល័យគយ លើកលែងតែក្នុងករណីប្រធានសក្តិ ដែលមានការបញ្ជាក់ហេតុផលច្បាស់លាស់ ។

**ប្រការ ១១ .-**

នៅពេលចូលដល់កំពង់ផែ នាវាបតីត្រូវផ្តល់សៀវភៅព័ត៌មាននាវា (Vessel's log book) ជូនមន្ត្រីគយដើម្បីចុះទិដ្ឋាការ ។

**ប្រការ ១២ .-**

ក្នុងរង្វង់ ២៤ ម៉ោង នៃការមកដល់កំពង់ផែ នាវាបតីត្រូវបង្ហាញជូនរដ្ឋបាលគយនូវឯកសារដូចខាងក្រោម ៖

១. របាយការណ៍នាវា

២. និវេទន៍ប័ណ្ណទំនិញ (ទុកដូចជាប្រតិវេទន៍បំព្រួញ)

៣. និវេទន៍ប័ណ្ណពិសេសសម្រាប់ឃ្លាំងសន្និធិក្នុងនាវា បញ្ជីឈ្មោះបុគ្គលិកនាវា បញ្ជីសម្ភារៈ ប្រើប្រាស់ផ្ទាល់ខ្លួនរបស់បុគ្គលិកនាវា

៤. កិច្ចសន្យាជួលនាវា ឬអញ្ញត្តិប័ណ្ណ វិញ្ញាបនប័ត្រចុះបញ្ជីនាវា និងឯកសារដទៃទៀតតាមការតម្រូវរបស់រដ្ឋបាលគយ ដើម្បីអនុវត្តវិធានការគយ ។

ប្រតិវេទន៍បំព្រួញត្រូវតែធ្វើផងដែរ ទោះបីនាវានោះគ្មានផ្ទុកទំនិញក៏ដោយ ។ ឯកសារទាំងអស់ត្រូវបានផ្តល់ដោយមានការបកប្រែត្រឹមត្រូវជាភាសាខ្មែរ ក្នុងករណីចាំបាច់ ។

តាមសំណើររបស់រដ្ឋបាលគយ និវេទន៍ប័ណ្ណនឹងត្រូវបានផ្តល់ជូនរដ្ឋបាលគយមុនការមកដល់នៃនាវា ។ បើអាចធ្វើទៅបាន និវេទន៍ប័ណ្ណត្រូវផ្តល់ជូនគយតាមទម្រង់អេឡិចត្រូនិក ។

**ប្រការ ១៣ .-**

ទូក និងជលយានដទៃទៀត ដែលមានទម្ងន់សរុបតិចជាងដប់ (១០) តោនត្រូវបាន តម្រូវឲ្យបង្ហាញទំនិញនៅកំពង់ផែទីមួយ ដែលមានការិយាល័យគយ ហើយស្ថិតនៅជិត បំផុតពីចំណុចចេញដំណើរ ។

**ប្រការ ១៤ .-**

ការរើទំនិញចេញពីនាវា អាចធ្វើបានតែក្នុងបរិវេណនៃកំពង់ផែដែលមាន ការិយាល័យគយតាំងនៅ ។

ការរើ ឬការផ្ទេរទំនិញចេញពីនាវា ត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី រដ្ឋបាលគយ និងដោយមានវត្តមានរបស់មន្ត្រីគយ ។

ការរើ និងការផ្ទេរទំនិញចេញពីនាវាត្រូវធ្វើនៅក្នុងពេលម៉ោងធ្វើការ របស់ ការិយាល័យគយ និងតាមលក្ខខណ្ឌដែលត្រូវបានកំណត់ដោយអគ្គនាយកគយ និងរដ្ឋាករ កម្ពុជា ។

នៅពេលបញ្ឈប់ប្រតិបត្តិការរើ ឬផ្ទុកទំនិញ បើយល់ថាចាំបាច់ មន្ត្រីគយអាចបិទ ឃុំបនាវា និងកិបសៀលគយ ដែលនឹងអាចត្រូវបានបើកឡើងវិញដោយមន្ត្រីគយ ។

**ប្រការ ១៥ .-**

សម្ភារៈប្រើប្រាស់នានានៅក្នុងនាវា ដែលត្រូវបានលើកលែងពន្ធ និងអាករ សម្រាប់ តម្រូវការប្រើប្រាស់ក្នុងនាវា ត្រូវរក្សាទុកក្នុងឃ្លាំង ដោយត្រូវកិបសៀលក្នុងករណីចាំបាច់ និង ត្រូវបង្ហាញជូនមន្ត្រីគយ ប្រសិនបើមានការតម្រូវ រហូតដល់ពេលនាវាចេញដំណើរ ។

**ប្រការ ១៦ .-**

ប្រសិនបើនាវាត្រូវបានបង្ខំឲ្យចូលចត នៅទឹកខ្សែងក្រៅពីកំពង់ផែដែលមាន ការិយាល័យគយ ដោយសារគ្រោះថ្នាក់ ឧបទ្ទវហេតុ ឬករណីប្រធានសក្តិ នាវាបតីត្រូវ បញ្ជាក់ហេតុផលក្នុងរបាយការណ៍ជាលាយល័ក្ខអក្សរជូនរដ្ឋបាលគយ ដោយពិពណ៌នាពី មូលហេតុនៃចំណតគ្រាអាសន្ននេះ ក្នុងរយៈពេល ២៤ ម៉ោង បន្ទាប់ពីការមកដល់ ។ នាវាបតីត្រូវ ប្រតិបត្តិតាមការតម្រូវដូចមានចែងក្នុងបញ្ញត្តិប្រការ ៨ ដល់ប្រការ ១៥ នៃប្រកាសនេះ ដើម្បីរាយការណ៍ពីការមកដល់នៃនាវា និងទំនិញរបស់ខ្លួន ជូនមន្ត្រីគយ ។

**ប្រការ ១៧ .-**

នៅពេលដែលសុវត្ថិភាពនៃនាវា ទំនិញ បុគ្គលិកនៅលើនាវា ឬមនុស្សដទៃទៀត ត្រូវរងនូវការគំរាមគំហែងដោយសាការបុកទង្គិចគ្នា អគ្គិភ័យ អាកាសធាតុមិនល្អ ឬការលិច នាវា ទំនិញអាចត្រូវបានរើចេញពីនាវានោះមុនពេលរាយការណ៍ជូនរដ្ឋបាលគយ ស្របតាម បញ្ញត្តិប្រការ១៦ នៃប្រកាសនេះ ។ ទោះជាយ៉ាងនេះក្តី នាវាបតីត្រូវជូនដំណឹងដល់អាជ្ញាធរ មូលដ្ឋានពាក់ព័ន្ធ មុននឹងផ្ទេរទំនិញចេញពីនាវា ។

ទំនិញផ្ទុកក្នុងនាវា ដែលត្រូវបានចូលចតក្នុងគ្រាអាសន្ន ហើយបានរាយការណ៍ ត្រឹមត្រូវនោះ មិនត្រូវជាកម្មវត្ថុនៃការជាប់ពន្ធ និងអាករឡើយ លើកលែងតែទំនិញទាំង នោះត្រូវបាននាំចូលមកកម្ពុជា ។

**ប្រការ ១៨ .-**

ទំនិញផ្ទុកក្នុងនាវា ដែលត្រូវបានរាយការណ៍ត្រឹមត្រូវពីការចូលចតក្នុងគ្រាអាសន្ន ជូនរដ្ឋបាលគយ ស្របតាមបញ្ញត្តិប្រការ ១៦ នៃប្រកាសនេះ អាចរើចេញពីនាវា និងសន្និធិ ទុកនៅកន្លែងមានសុវត្ថិភាពក្រោមបន្ទុកចំណាយរបស់ប្រតិបត្តិករនាវា ឬម្ចាស់ ។ ត្រូវជូន ដំណឹងដល់រដ្ឋបាលគយជាបន្ទាន់ពីទីកន្លែងនៃសន្និធិនោះ ដែលនឹងត្រូវបានរក្សាសុវត្ថិភាព ដោយប្រព័ន្ធសោពីរ ។ មន្ត្រីគយត្រូវរក្សាទុកកូនសោមួយរហូតដល់ពេលដែលទំនិញត្រូវ បានយកចេញពីទីកន្លែងនោះដើម្បីនាំចេញទៅវិញ ឬដើម្បីនាំចូលមកកម្ពុជា ។ ប្រតិវេទន៍ គយបំពេញត្រូវដាក់ជូនការិយាល័យគយជិតបំផុតក្នុងរយ:ពេល ២៤ ម៉ោង នៃការផ្ទេរទំនិញ ចេញពីនាវា ស្របតាមបញ្ញត្តិនានានៃប្រកាសនេះ ។

ប្រតិបត្តិករនាវា ត្រូវបានអនុញ្ញាតឲ្យផ្ទេរទំនិញពីនាវាមួយ ទៅនាវាមួយទៀត បន្ទាប់ពីប្រតិវេទន៍គយបំពេញត្រូវបានបំពេញ ស្របតាមបញ្ញត្តិនានានៃប្រកាសនេះ ។

**ប្រការ ១៩ .-**

លើកលែងតែមានភស្តុតាងផ្ទុយ នាវាដែលបានលិច បំណែកនាវាលិច និងទំនិញ ដែលត្រូវបានរកឃើញពីនាវាដូចនេះ ដែលប្រមូលបាន នៅតាមបណ្តោយឆ្នេរ ឬក្នុងសមុទ្រ ត្រូវចាត់ទុកជា ជាទំនិញបរទេស និងត្រូវជាកម្មវត្ថុនៃការរាយការណ៍ជូនរដ្ឋបាលគយ ។ ទំនិញ និងនាវាលិចត្រូវរក្សាទុកក្រោមការគ្រប់គ្រងរបស់គយ ដើម្បីរង់ចាំការបំពេញទម្រង់ ការគយ ។

**ប្រការ ២០ .-**

ទំនិញទាំងឡាយដែលបាននាំចូលតាមព្រំដែនគោក ត្រូវនាំទៅកាន់ការិយាល័យគយជិតបំផុតតាមតម្រាយផ្លូវស្របច្បាប់ ។

ទំនិញទាំងនេះពុំអាចត្រូវបានយកទៅដាក់ក្នុងលំនៅដ្ឋាន ឬអាគារដទៃទៀត មុននឹងនាំមកកាន់ការិយាល័យគយជិតបំផុត ឬគេចវេសការិយាល័យគយ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយឡើយ ។

**ប្រការ ២១ .-**

នៅពេលមកដល់ការិយាល័យគយ អ្នកដឹកជញ្ជូនត្រូវផ្តល់ជូនរដ្ឋបាលគយនូវប្រតិវេទន៍បំព្រួញ ឬយ៉ាងហោចណាស់ប័ណ្ណដឹកជញ្ជូនទំនិញដែលខ្លួនបានដឹកជញ្ជូន ។

ទំនិញហាមឃាត់ទាំងឡាយ ត្រូវបានកត់ត្រានៅក្នុងប្រតិវេទន៍បំព្រួញ ដោយមានបរិយាយត្រឹមត្រូវនូវលក្ខណៈសម្គាល់ និងប្រភេទទំនិញទាំងនេះ ។

ប្រសិនបើប្រតិវេទន៍គយលម្អិតត្រូវបានធ្វើនាពេលមកដល់ការិយាល័យគយ នោះនឹងមិនតម្រូវឱ្យមានការធ្វើប្រតិវេទន៍បំព្រួញឡើយ ។

**ប្រការ ២២ .-**

ទំនិញទាំងអស់ដែលដឹកជញ្ជូនតាមផ្លូវអាកាសត្រូវបានកត់ត្រានៅលើនិវេទន៍ប័ណ្ណដែលមានចុះហត្ថលេខារបស់អាកាសយានបតី ។ និវេទន៍ប័ណ្ណនេះត្រូវបានធ្វើឡើងតាមរបៀបដូចគ្នានឹងនិវេទន៍ប័ណ្ណនាវា តាមបញ្ញត្តិប្រការ ១២ នៃប្រកាសនេះ ។

**ប្រការ ២៣ .-**

នាពេលសួររក អាកាសយានបតីត្រូវផ្តល់ជូនរដ្ឋបាលគយជាបន្ទាន់នូវនិវេទន៍ប័ណ្ណរួមជាមួយឯកសារពាក់ព័ន្ធដទៃទៀត ។ អាកាសយានបតីត្រូវតម្កល់ឯកសារទាំងនេះនៅការិយាល័យគយតាមអាកាសយានដ្ឋាន នាពេលមកដល់នៃអាកាសយាន ដោយចាត់ទុកជាប្រតិវេទន៍បំព្រួញ ។

**ប្រការ ២៤ .-**

ត្រូវបានហាមឃាត់មិនឲ្យរើ និងទម្លាក់ទំនិញនៅតាមផ្លូវហោះហើរ ។ ទោះជាយ៉ាងណាក្តី អាកាសយានបតីមានសិទ្ធិរើ ឬទំលាក់ដើម្បីដោះបន្ទុកទម្ងន់ តាមផ្លូវហោះហើរនូវវត្ថុនានារួមទាំង ឧបករណ៍រក្សាលំនឹង កញ្ចប់ឯកសារ និងទំនិញ ដើម្បីជានាសុវត្ថិភាពអាកាសយាន ។

បញ្ញត្តិប្រការ ១៤ នៃប្រកាសនេះ ក៏ត្រូវបានអនុវត្តផងដែរចំពោះការបើ និងការផ្ទេរ ទំនិញ តាមផ្លូវអាកាស ។

**ប្រការ ២៥ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២៦ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៦
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៣៩-០៧០-៥៤១ ប្រ.ក

# ប្រកាស
# ស្តីពី
# អ្នកដំណើរការតតិយភាគី

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមការអនុម័តិរបស់អង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០

# សម្រេច
## ជំពូក ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

គោលបំណងរបស់ប្រកាសនេះគឺដើម្បីផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារ ដែលបានកំណត់ដោយច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ តទៅនេះហៅថា "ធនាគារ" ដើម្បីប្រគល់មួយផ្នែក ឬ

ច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់ ឱ្យអ្នកដំណើរការតតិយភាគីមួយឬច្រើន ដូចដែលបានព្រមព្រៀងគ្នារវាងធនាគារ និងអ្នកដំណើរការតតិយភាគីទាំងនោះ និងដែលត្រូវមានការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជាស្របតាមមាត្រា២០៤ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

**ប្រការ ២.-**

**អ្នកដំណើរការតតិយភាគី** ( **Third-Party Processor** ) សំដៅដល់បុគ្គលដែលធនាគារបានប្រគល់សិទ្ធិឱ្យធ្វើប្រតិបត្តិការលើមួយផ្នែក ឬច្រើនផ្នែកនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់របស់ធនាគារនោះ ។

**ការផ្តល់សេវាពីខាងក្រៅ** (**Outsourcing**) សំដៅដល់ការប្រគល់សេវាមួយផ្នែក ឬច្រើនផ្នែកដែលធនាគារបានព្រមព្រៀងជាមួយបុគ្គល ឬធនាគារមួយផ្សេងទៀតដើម្បីធ្វើសេវានោះជំនួសខ្លួន ។

## ជំពូក ២
## សេវាប្រតិបត្តិការទូទាត់សងប្រាក់

**ប្រការ ៣.-**

១- បុគ្គលដែលមិនមែនជាធនាគារមិនអាចធ្វើអាជីវកម្មពាក់ព័ន្ធនឹងប្រតិបត្តិការទូទាត់សងប្រាក់ ឬតាំងខ្លួនឯងជាអ្នកផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់បានឡើយ លុះត្រាតែបុគ្គលនោះ ៖

ក) ត្រូវបានធនាគារអនុញ្ញាតឱ្យធ្វើជាអ្នកដំណើរការតតិយភាគីរបស់ខ្លួនតាមការព្រមព្រៀងគ្នា និង

ខ) បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា

២- នៅពេលទទួលបានការអនុញ្ញាតពីធនាគារ និងទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អ្នកដំណើរការតតិយភាគីអាចផ្តល់សេវាមួយផ្នែក ឬច្រើនផ្នែកជំនួសឲ្យធនាគារ ដូចមានចែងនៅក្នុងមាត្រា ២០៣ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ដូចខាងក្រោម៖

ក) ជាអ្នកទំនាក់ទំនង

ខ) ជាអ្នកជាត់ទាត់អន្តរធនាគារដែលអាចបញ្ជូនជាបន្តនូវព័ត៌មានអំពីការទូទាត់អន្តរធនាគារទៅធនាគារនានា រួមទាំងធនាគារជាកន្លែងដែលការទូទាត់ត្រូវបានបញ្ចប់ផងដែរ

គ) ជាអ្នកគ្រប់គ្រង ឬជាអ្នកធ្វើប្រតិបត្តិការលើគណនីអតិថិជនរបស់ធនាគារ និង/ឬ

ឃ) ដើរតួជាកន្លែងផ្ញើ និងទទួលបញ្ជាទូទាត់ដែលត្រូវបានផ្ញើ ឬទទួលដោយធនាគារ ហើយដែលអតិថិជនរបស់ធនាគារអាចចូលទាក់ទងដោយផ្ទាល់សម្រាប់ការផ្ញើ និង ទទួលបញ្ជាទូទាត់ ។ បន្ថែមលើនេះ៖

ង) ជាអ្នកផ្តល់សេវាផ្ទេរប្រាក់តាមទូរស័ព្ទចល័ត ឬតាមមធ្យោបាយផ្សេងទៀត

ច) ជាអ្នកផ្តល់សេវាផាត់ទាត់ និងទូទាត់ ការទូទាត់សងប្រាក់ដោយប័ណ្ណឥណទាន ឬ ប័ណ្ណឥណពន្ធ

**ប្រការ ៤.-**

១- អ្នកដំណើរការតតិយភាគីអាចគ្រប់គ្រង និងធ្វើប្រតិបត្តិការជំនួសឱ្យធនាគារមួយ ឬ ច្រើននូវប្រព័ន្ធទូទាត់សងប្រាក់ សម្រាប់ ៖

ក) ប្រតិបត្តិការទូទាត់សងប្រាក់ និងការដកសាច់ប្រាក់

ខ) ការផាត់ទាត់ និងទូទាត់ នៅក្នុងប្រទេសកម្ពុជាសម្រាប់ឧបករណ៍ទូទាត់សងប្រាក់ជា រូបិយវត្ថុក្នុងស្រុក និងជារូបិយប័ណ្ណ

២- ក្នុងករណីនេះ អ្នកដំណើរការតតិយភាគីត្រូវតែបានទទួលការអនុញ្ញាតឱ្យធ្វើសេវាបែប នេះដោយធនាគារមួយ និងធនាគារទាំងអស់ដែលចូលរួមនៅក្នុងប្រព័ន្ធទូទាត់ ហើយការទទួលខុស ត្រូវរបស់ធនាគារនីមួយៗ ត្រូវតែបានបែងចែកឱ្យបានត្រឹមត្រូវ ។

**ប្រការ ៥.-**

អ្នកដំណើរការតតិយភាគីដែលគ្រប់គ្រងប្រព័ន្ធទូទាត់នឹងត្រូវស្ថិតនៅក្រោមប្រកាសស្តីពី ប្រព័ន្ធផាត់ទាត់នៃការទូទាត់សងប្រាក់ ប្រកាសស្តីពីការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធ នៃប្រព័ន្ធទូទាត់សងប្រាក់ និងប្រកាសស្តីពីប្រតិបត្តិការនៃគណនីទូទាត់ដែលមានស្រាប់របស់ធនាគារ ជាតិនៃកម្ពុជា និងវិធានការពាក់ព័ន្ធផ្សេងៗទៀតប្រសិនបើមាន ។

## ជំពូក ៣

## ការស្នើសុំអាជ្ញាប័ណ្ណសម្រាប់អ្នកដំណើរការតតិយភាគីរបស់ធនាគារ

**ប្រការ ៦.-**

១- មុនពេលអនុញ្ញាតឱ្យអ្នកដំណើរការតតិយភាគីធ្វើសេវាប្រតិបត្តិការទូទាត់សងប្រាក់ ធនាគារត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាជំនួសឲ្យអ្នកដំណើរការតតិយភាគី ។ ពាក្យស្នើសុំនេះត្រូវតែបញ្ជាក់ ឬមានព័ត៌មានដូចតទៅ ៖

ក) ឈ្មោះផ្លូវការ អាសយដ្ឋានរស់នៅនិងអាសយដ្ឋានធ្វើអាជីវកម្មរបស់អ្នកដំណើរការតតិយភាគី និងសម្មតិនាមឬឈ្មោះពាណិជ្ជកម្មដែលអ្នកដំណើរការតតិយភាគីបានប្រើប្រាស់ក្នុងការធ្វើអាជីវកម្មរបស់ខ្លួនជំនួសឱ្យធនាគារ និងការពិពណ៌នាអំពីស្ថានភាពស្របច្បាប់របស់ខ្លួន ។

ខ) ការពិពណ៌នាអំពីសេវាប្រតិបត្តិការទូទាត់សងប្រាក់ដែលពីមុនអ្នកដំណើរការតតិយភាគីធ្លាប់បានផ្តល់នៅក្នុងនិងក្រៅប្រទេសកម្ពុជាប្រសិនបើមាន និងសេវាប្រតិបត្តិការទូទាត់សងប្រាក់ ដែលអ្នកដំណើរការតតិយភាគីមានបំណងផ្តល់នៅក្នុងប្រទេសកម្ពុជាជំនួសឱ្យធនាគារ ។

គ) ការពិពណ៌នាអំពីមធ្យោបាយស្របច្បាប់ដែលត្រូវអនុវត្ត ដើម្បីការពារមូលនិធិរបស់អតិថិជនពីហានិភ័យណាមួយដែលបណ្តាលមកពីការផ្តល់សេវាពីខាងក្រៅនេះ ការប្រឆាំងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងកាតព្វកិច្ចស្គាល់អតិថិជនរបស់ខ្លួន ព្រមទាំងវិធានការនានាដើម្បីឱ្យអតិថិជនបានដឹងអំពីតួនាទីរបស់អ្នកដំណើរការតតិយភាគីនៅក្នុងសេវាប្រតិបត្តិការទូទាត់សងប្រាក់។ ក្នុងករណីប្រើប្រាស់ភ្នាក់ងារ ចាំបាច់ត្រូវពណ៌នាអំពីមុខងារ និងស្ថានភាពស្របច្បាប់របស់ភ្នាក់ងារទាំងនោះ ។

២- ពាក្យស្នើសុំត្រូវតែភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម ៖

- សេចក្តីសម្រេចរបស់គណៈគ្រប់គ្រងធនាគារសាមីដែលអនុញ្ញាតឱ្យធនាគារប្រគល់សេវាប្រតិបត្តិការទូទាត់សងប្រាក់របស់ខ្លួនមួយផ្នែក ឬច្រើនផ្នែក ទៅឱ្យអ្នកដំណើរការតតិយភាគី
- កិច្ចព្រមព្រៀងរវាងធនាគារនិងអ្នកដំណើរការតតិយភាគី ដើម្បីប្រគល់និងទទួលសេវានេះ
- ការអនុញ្ញាតពីក្រុមហ៊ុនមេ ឬទីស្នាក់ការកណ្តាល ប្រសិនបើមាន ដើម្បីអនុញ្ញាតឱ្យសាខា ឬបុត្តសម្ព័ន្ធរបស់ខ្លួនធ្វើជាអ្នកដំណើរការតតិយភាគី
- លិខិតធានារបស់ធនាគារដែលសន្យាទទួលខុសត្រូវទាំងស្រុងលើសកម្មភាពរបស់អ្នកដំណើរការតតិយភាគី

៣- ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវភ្ជាប់ជាមួយសោហ៊ុយ ចំនួន ២.០០០.០០០ រៀល (ពីរលានរៀល) ។

៤- ធនាគារត្រូវបង់សោហ៊ុយអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន ១០.០០០.០០០ រៀល (ដប់លានរៀល) ជំនួសឱ្យអ្នកដំណើរការតតិយភាគីឱ្យបានត្រឹមថ្ងៃទី១៥ ខែមករា ។

៥- ចំពោះធនាគារដែលស្នើសុំអាជ្ញាប័ណ្ណសម្រាប់អ្នកដំណើរការតតិយភាគីនៅក្នុងឆ្នាំ

សោហ៊ុយអាជ្ញាប័ណ្ណនឹងត្រូវបានគណនាតាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

៦- ក្នុងករណីការបង់សោហ៊ុយអាជ្ញាប័ណ្ណមានការយឺតយ៉ាវ ធនាគារពាក់ព័ន្ធត្រូវទទួលរងនូវការផាកពិន័យដោយត្រូវបង់ការប្រាក់លើចំនួនប្រាក់ដែលនៅមិនទាន់បានបង់តាមអត្រាការប្រាក់បុនហិរញ្ញប្បទានជាធរមាន ក្នុងរយៈពេលរហូតដល់ ៣០ ថ្ងៃ (សាមសិបថ្ងៃ) ។

**ប្រការ ៧.-**

១- អាជ្ញាប័ណ្ណមានសុពលភាពសម្រាប់រយៈពេល៣ឆ្នាំ គិតចាប់ពីពេលបានចេញឱ្យ ។ អាជ្ញា-ប័ណ្ណនេះអាចស្នើសុំបន្តជាថ្មីបាន លុះត្រាតែអ្នកដំណើរការតតិយភាគីធ្វើសកម្មភាពស្របតាមច្បាប់ និងបទប្បញ្ញត្តិនានា ហើយរាល់ការប្រព្រឹត្តល្មើសច្បាប់ និងបទបញ្ជាប្រុងប្រយ័ត្ន ប្រសិនបើមាន ត្រូវបានដោះស្រាយ ។

២- ពាក្យស្នើសុំអាជ្ញាប័ណ្ណជាថ្មីត្រូវដាក់ជូនធនាគារជាតិនៃកម្ពុជា យ៉ាងយឺតបំផុត ៣ ខែ (បីខែ) មុនពេលអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ផុតសុពលភាព ។ ក្នុងករណីដែលការស្នើសុំនោះមានបញ្ចូលសេវាថ្មី ឬមានវិធីខុសគ្នាច្រើនចំពោះការផ្តល់សេវាដូចគ្នា ធនាគារជាតិនៃកម្ពុជាត្រូវពិចារណាលើបញ្ហានេះដោយចាត់ទុកថាជាការស្នើសុំអាជ្ញាប័ណ្ណថ្មី ។

៣- ក្នុងករណីមិនបានដាក់ពាក្យស្នើសុំបន្តតាមកាលកំណត់ខាងលើនេះទេ ធនាគារត្រូវទទួលរងការផាកពិន័យជាប្រាក់ចំនួន ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃរហូតដល់ថ្ងៃបានដាក់ពាក្យស្នើសុំនេះ ។

៤- ធនាគារដែលនៅតែមិនអាចគោរពតាមកាលបរិច្ឆេទកំណត់ ឬតាមពេលវេលាដែលធនាគារជាតិនៃកម្ពុជាបានពន្យារឱ្យនោះទេ នឹងត្រូវទទួលរងនូវការព្យួរអាជ្ញាប័ណ្ណរបស់អ្នកដំណើរការតតិយភាគី ។ ការព្យួរអាជ្ញាប័ណ្ណនឹងត្រូវបានលុបចោលវិញ ប្រសិនបើក្នុងរយៈពេល២០ថ្ងៃបន្ទាប់ពីអាជ្ញាប័ណ្ណត្រូវបានព្យួរ ធនាគារបាន ៖

ក) ដាក់ពាក្យស្នើសុំ និងបង់សោហ៊ុយអាជ្ញាប័ណ្ណជាថ្មីឱ្យអ្នកដំណើរការតតិយភាគី និង

ខ) បង់ប្រាក់ពិន័យចំនួន ២០០.០០០ រៀល (ម្ភៃម៉ឺនរៀល) ក្នុងមួយថ្ងៃ ក្រោយពេលព្យួរអាជ្ញាប័ណ្ណ

៥- ប្រសិនបើធនាគារនៅតែមិនអាចបំពេញបាននូវចំណុច៤ខាងលើ ធនាគារនោះនឹងត្រូវទទួលរងនូវការផាកពិន័យកាន់តែធ្ងន់ធ្ងរឡើង ដែលអាចនឹងឈានទៅដល់ការដកអាជ្ញាប័ណ្ណអ្នកដំណើរការតតិយភាគីតែម្តង ។

**ប្រការ ៨.-**

១- ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការយល់ព្រម ឬបដិសេធពាក្យស្នើសុំនេះក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) ក្រោយពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំពេញលេញ ។

២- ធនាគារជាតិនៃកម្ពុជាអាចពន្យាររយៈពេលនៃការដាក់ពាក្យស្នើសុំ ប្រសិនបើមានមូលហេតុសមស្រប ។

៣- អាជ្ញាប័ណ្ណត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីសេវា ឬសកម្មភាពទាំងឡាយដែលត្រូវបានអនុញ្ញាតនិង/ឬត្រូវបានរឹតត្បិតចំពោះវិសាលភាព ឬមធ្យោបាយក្នុងការផ្តល់សេវាបែបនេះ ។

៤- ធនាគារជាតិនៃកម្ពុជាអាចស្នើទៅគ្រឹះស្ថានធនាគារ និងអ្នកដំណើរការតតិយភាគី ដើម្បីកែប្រែផ្នែកខ្លះនៃកិច្ចព្រមព្រៀងដែលបានចុះហើយ ប្រសិនបើពិនិត្យឃើញថាកិច្ចព្រមព្រៀងទាំងនេះអាចនាំឱ្យមានហានិភ័យហួសប្រមាណចំពោះប្រព័ន្ធជាតិទូទាត់សងប្រាក់ ឬទីផ្សារ ។

**ប្រការ ៩.-**

១- ធនាគារដែលប្រគល់សិទ្ធិក្នុងការធ្វើសេវាប្រតិបត្តិការទូទាត់សងប្រាក់មួយផ្នែក ឬច្រើនផ្នែកទៅឱ្យអ្នកដំណើរការតតិយភាគី ត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណឡើងវិញក្នុងរយៈពេលមិនឱ្យលើស ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនពេលអាជ្ញាប័ណ្ណដែលកំពុងប្រើប្រាស់ផុតសុពលភាព ។ ធនាគារត្រូវបំពេញកាតព្វកិច្ចផ្តល់ព័ត៌មាន និងបង់សោហ៊ុយបន្តអាជ្ញាប័ណ្ណជាថ្មីជួសមុខឱ្យអ្នកដំណើរការតតិយភាគី ។

២- ពាក្យស្នើសុំអាជ្ញាប័ណ្ណជាថ្មី ត្រូវមានភ្ជាប់ជាមួយនូវ ៖

ក) ច្បាប់ចម្លងនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលបានធ្វើសវនកម្មនាពេលថ្មីៗបំផុតរបស់ធនាគារ ។

ខ) ការពិពណ៌នាអំពីការកែប្រែព័ត៌មានសំខាន់ៗរបស់អ្នកដំណើរការតតិយភាគីនៅក្នុងពាក្យស្នើសុំអាជ្ញាប័ណ្ណដំបូងរបស់ខ្លួន ដែលមិនបានរាយការណ៍ជូនធនាគារជាតិនៃកម្ពុជានៅក្នុងរបាយការណ៍ដែលបានតម្រូវ ។

គ) បញ្ជីទីតាំងនៅក្នុងប្រទេសកម្ពុជាដែលអ្នកដំណើរការតតិយភាគីធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ឬផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់ផ្សេងៗទៀត ។

ឃ)ការបង្ហាញឱ្យដឹងពីការតវ៉ាធ្ងន់ធ្ងរណាមួយ ឬសកម្មភាពស្របច្បាប់ដែលទទួលធ្វើដោយអតិថិជន ឬភាគីទីបីដែលទាក់ទងនឹងសេវាកម្មផ្តល់អាជ្ញាប័ណ្ណ ។

## ជំពូក ៤
## ភារកិច្ច និងការទទួលខុសត្រូវរបស់ធនាគារ

**ប្រការ ១០.-**

ធនាគារដែលបានទទួលអាជ្ញាប័ណ្ណសម្រាប់អ្នកដំណើរការតតិយភាគីត្រូវ ៖

១- ទទួលខុសត្រូវទាំងស្រុងលើសកម្មភាព ឬកំហុសឆ្គងនានារបស់អ្នកដំណើរការតតិយភាគីនិងភ្នាក់ងារដែលធ្វើសកម្មភាពក្រោមការប្រគល់សិទ្ធិរបស់ខ្លួន និងជំនួសឱ្យខ្លួន ។

២- ត្រូវធានាថា អ្នកដំណើរការតតិយភាគីធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួនចំពោះរាល់សកម្មភាព ដែលក្នុងនោះអ្នកដំណើរការតតិយភាគីបានធ្វើសកម្មភាពជំនួសឱ្យខ្លួន ដើម្បីធានានូវការគោរពតាមប្រកាសនេះ និងកាតព្វកិច្ចខាងផ្នែកគតិយុត្តផ្សេងៗទៀត ។ ធនាគារមិនអាចបដិសេធចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យនេះបានទេ ។

៣- ត្រូវធានាថា អ្នកដំណើរការតតិយភាគីដែលធ្វើសកម្មភាពជំនួសឲ្យខ្លួន និងភ្នាក់ងារប្រតិស្រុត បានជម្រាបជូនអតិថិជនអំពីការទទួលខុសត្រូវនេះ ។

៤- ត្រូវធានាថា សេវាផ្តល់ដោយអ្នកដំណើរការតតិយភាគី មានសុវត្ថិភាព និងការធានាផ្នែកបច្ចេកទេសនិងប្រតិបត្តិការសមស្រប ដើម្បីផ្តល់នូវ៖

ក) ឯកសារសវនកម្ម និងកំណត់ត្រាតែមួយនៃការផ្តល់សេវា

ខ) ការធ្វើរបាយការណ៍ ការស៊ើបអង្កេត និងការបញ្ជាក់ ក្នុងអតិថិជនម្នាក់ៗនិងការផ្តល់សេវាម្តងៗ

គ) ការបដិសេធ និងការស្វែងរកប្រកបដោយភាពជឿជាក់លើការផ្តល់សេវាដែលមិនបានសម្រេចនិងដែលលួចបន្លំ

ឃ) ការថែរក្សាទុកកំណត់ត្រាឲ្យបានត្រឹមត្រូវប្រកបដោយសុវត្ថិភាព ។

**ប្រការ ១១.-**

ទំនាក់ទំនង និងកាតព្វកិច្ចរបស់ធនាគារចំពោះអតិថិជនរបស់ខ្លួនមិនត្រូវបានប៉ះពាល់ដោយសារតែការប្រើប្រាស់សេវាពីខាងក្រៅនៃសកម្មភាពណាមួយដែលស្ថិតនៅក្រោមប្រកាសនេះទេ ។

## ជំពូក ៥
## តួនាទី និងការទទួលខុសត្រូវរបស់អ្នកដំណើរការតតិយភាគី

**ប្រការ ១២.-**

អ្នកដំណើរការតតិយភាគីដែលធ្វើសកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ជំនួសឱ្យធនាគារមានភារកិច្ច ដូចតទៅ ៖

១- អាចជ្រើសរើសភ្នាក់ងារមួយឬច្រើន ដើម្បីជួយដល់ប្រតិបត្តិការដាក់និងដកសាច់ប្រាក់។

២- ត្រូវមានកិច្ចសន្យាតាមផ្លូវច្បាប់ជាមួយភ្នាក់ងារដែលបានជ្រើសរើស និងត្រូវកំណត់គោលការណ៍ និងនីតិវិធីឱ្យបានច្បាស់លាស់ដើម្បីឱ្យភ្នាក់ងារនេះគោរពតាមទាំងស្រុង ។

៣- ត្រូវធានាថាភ្នាក់ងារដែលបានជ្រើសរើសមិនផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់នៅក្រៅដែនសកម្មភាពអនុញ្ញាតដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងភ្នាក់ងារ និងអ្នកដំណើរការតតិយភាគីឡើយ ។

៤- ត្រូវធានាថា សេវាផ្តល់ដោយខ្លួនឯងផ្ទាល់ ឬភ្នាក់ងារណាមួយដែលខ្លួនតែងតាំង មានសុវត្ថិភាព និងការធានាផ្នែកបច្ចេកទេសនិងប្រតិបត្តិការសមស្រប ដើម្បីផ្តល់នូវៈ

ក) ឯកសារសវនកម្ម និងកំណត់ត្រាតែមួយនៃការផ្តល់សេវា

ខ) ការធ្វើរបាយការណ៍ ការស៊ើបអង្កេត និងការបញ្ជាក់ ក្នុងអតិថិជនម្នាក់ៗនិងការផ្តល់សេវាម្តងៗ

គ) ការបដិសេធនិងការស្វែងរកប្រកបដោយភាពជឿជាក់លើការផ្តល់សេវាដែលមិនបានសម្រេចនិងដែលលួចបន្លំ

ឃ) ការថែរក្សាទុកកំណត់ត្រាឲ្យបានត្រឹមត្រូវប្រកបដោយសុវត្ថិភាព ។

**ប្រការ ១៣**.-

អ្នកដំណើរការតតិយភាគីមានកាតព្វកិច្ចទទួលខុសត្រូវទាំងស្រុងលើរាល់សកម្មភាពប្រតិបត្តិការរបស់ខ្លួន រួមទាំងសកម្មភាពរបស់ភ្នាក់ងារដែលខ្លួនបានជ្រើសរើស ដូចតទៅ ៖

១- ទទួលខុសត្រូវលើរាល់សកម្មភាព ឬរាល់កំហុសរបស់ភ្នាក់ងារប្រតិស្រុតដែលផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់ជំនួសឲ្យខ្លួន ទាំងចំពោះតតិយភាគីផង និងចំពោះធនាគារផង ។

២- ត្រូវធានាថា ភ្នាក់ងាររបស់ខ្លួនធ្វើប្រតិបត្តិការនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យទាំងស្រុងរបស់ខ្លួនចំពោះរាល់សកម្មភាពដែលក្នុងនោះភ្នាក់ងារបានធ្វើជំនួសឲ្យខ្លួន។ អ្នកដំណើរការតតិយភាគី មិនអាចបដិសេធចំពោះការគ្រប់គ្រង និងការត្រួតពិនិត្យនេះបានទេ ។

៣- ត្រូវផ្តល់បញ្ជីឈ្មោះភ្នាក់ងាររបស់ខ្លួន រួមទាំងឈ្មោះ និងអាសយដ្ឋាននៃទីតាំងដែលភ្នាក់ងារទាំងនោះធ្វើប្រតិបត្តិការទូទាត់សងប្រាក់ ដោយមានការបញ្ជាក់ពីធនាគារពាក់ព័ន្ធមកធនាគារជាតិនៃកម្ពុជាជារៀងរាល់ខែ ។

## ជំពូក ៦
## ការគ្រប់គ្រងគណនី

**ប្រការ ១៤**.-

ធនាគារដែលបានប្រគល់សិទ្ធិឱ្យអ្នកដំណើរការតតិយភាគីធ្វើសេវាប្រតិបត្តិការផ្ទេរប្រាក់ត្រូវតម្រូវឱ្យអ្នកដំណើរការតតិយភាគីបើកគណនីនៅធនាគាររបស់ខ្លួន ដើម្បីតម្កល់ប្រាក់ដែលទទួលបានពីអតិថិជនសម្រាប់ធ្វើការផ្ទេរ ដូចជាការផ្ទេរតាមទូរស័ព្ទជាដើម។

គណនីរបស់អ្នកដំណើរការតតិយភាគីនេះ មានរូបភាពជាគណនីអាណត្តិព្យាបាលសម្រាប់តម្កល់ប្រាក់ជាបណ្តោះអាសន្ន ដែលនឹងត្រូវបានប្រើសម្រាប់តែការផ្ទេររបស់អតិថិជនប៉ុណ្ណោះ និងមិនត្រូវបានប្រើប្រាស់ក្នុងគោលដៅផ្សេងឡើយ។

ធនាគារសាមីមានតួនាទី តាមដានត្រួតពិនិត្យគណនីនេះជាប្រចាំ ហើយក្នុងករណីមានការបញ្ឈប់សកម្មភាពរបស់អ្នកដំណើរការតតិយភាគី ឬអ្នកដំណើរការតតិយភាគីក្ស័យធន ធនាគារត្រូវតែឃាត់ទុកគណនីនេះ ដើម្បីជាផលប្រយោជន៍របស់អតិថិជន។ សមតុល្យនៃគណនីនេះ មិនមែនជាទ្រព្យសម្បត្តិរបស់អ្នកដំណើរការតតិយភាគីឡើយ។

## ជំពូក ៧
## ការត្រួតពិនិត្យ របាយការណ៍ និងកំណត់ត្រា

**ប្រការ១៥**.-

១- ធនាគារជាតិនៃកម្ពុជាអាចត្រួតពិនិត្យប្រចាំឆ្នាំចំពោះអ្នកដំណើរការតតិយភាគី ឬប្រសិនបើចាំបាច់ចំពោះធនាគារ បន្ទាប់ពីបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនចំនួន ៣០ ថ្ងៃ (សាមសិបថ្ងៃ) ។

២- ធនាគារជាតិនៃកម្ពុជាអាចត្រួតពិនិត្យអ្នកដំណើរការតតិយភាគីនៅពេលណាមួយក៏បាន ដោយពុំមានការជូនដំណឹងជាមុនឡើយ ប្រសិនបើធនាគារជាតិនៃកម្ពុជាមានហេតុផលជឿថា អ្នកដំណើរការតតិយភាគីកំពុងធ្វើសកម្មភាពមិនត្រឹមត្រូវ ឬគ្មានសុវត្ថិភាព ឬបានបំពាន ឬកំពុងរំលោភប្រកាសនេះ ឬបទបញ្ជាដែលចេញផ្សាយក្រោមប្រកាសនេះ ។

៣- ប្រសិនបើធនាគារជាតិនៃកម្ពុជាសម្រេចថា ការត្រួតពិនិត្យដល់ទីកន្លែងដូចមានចែងក្នុងចំណុច១និង២ខាងលើជាការចាំបាច់ អ្នកដំណើរការតតិយភាគី ឬធនាគារត្រូវទទួលបន្ទុកលើចំណាយសមស្របនៃការត្រួតពិនិត្យនោះ ។

៤- ព័ត៌មានដែលទទួលបានក្នុងអំឡុងពេលត្រួតពិនិត្យដែលមានចែងក្នុងប្រកាសនេះ អាចនឹងត្រូវបានបើកចំហដោយអនុលោមតាមប្រការ ១៧ តែប៉ុណ្ណោះ ។

**ប្រការ ១៦**.-

១- អ្នកដំណើរការតតិយភាគីត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ១៥ ថ្ងៃ(ដប់ប្រាំថ្ងៃ) នៃថ្ងៃធ្វើការ នូវរាល់ការកែប្រែព័ត៌មានសំខាន់ៗដែលបានផ្តល់ឱ្យនៅក្នុងពាក្យស្នើសុំអាជ្ញាប័ណ្ណដូចដែលបានតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

២- ដោយមានការបញ្ជាក់ពីធនាគារពាក់ព័ន្ធ អ្នកដំណើរការតតិយភាគីត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) បន្ទាប់ពីចុងត្រីមាសនីមួយៗ នូវ ៖

ក) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៃប្រតិបត្តិការទូទាត់សងប្រាក់រួមទាំងតារាងតុល្យការ និងរបាយការណ៍ចំណូល-ចំណាយ ។

ខ) សកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់រួមទាំងរបាយការណ៍សរុបអំពីសកម្មភាពនានាប្រចាំខែដោយបែងចែកទៅតាមប្រភេទផ្សេងៗ តាមការណែនាំរបស់ធនាគារពាក់ព័ន្ធ។

គ) បញ្ជីសេវានានាដែលអ្នកដំណើរការតតិយភាគីកំពុងធ្វើនាពេលបច្ចុប្បន្ន និងថ្ងៃនិងពេលវេលានៃការផ្តល់សេវាប្រតិបត្តិការទូទាត់សងប្រាក់ ។

ឃ) ព័ត៌មានផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ១៧**.-

១- អ្នកដំណើរការតតិយភាគី ត្រូវរក្សាទុកនូវរាល់កំណត់ត្រាសកម្មភាពនានារបស់ខ្លួនអំពីព័ត៌មានប្រតិបត្តិការនីមួយៗយ៉ាងហោចណាស់រយៈពេល ១០ ឆ្នាំ (ដប់ឆ្នាំ) និងជាពិសេសត្រូវរក្សាទុកកំណត់ត្រាសម្រាប់បញ្ជាក់នូវការគោរពតាមរបស់អ្នកដំណើរការតតិយភាគីចំពោះប្រកាសនេះដូចខាងក្រោម ៖

ក) កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗ

ខ) សៀវភៅធំដែលបានចុះបញ្ជីយ៉ាងហោចណាស់ប្រចាំខែ អំពីគណនីទ្រព្យសកម្ម ទ្រព្យអកម្ម ដើមទុន ចំណូល និងចំណាយ

គ) របាយការណ៍គណនី និងកំណត់ត្រាផ្ទៀងផ្ទាត់របស់ធនាគារ

ឃ) កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់ដែលមិនទាន់បានទូទាត់សង

ង) កំណត់ត្រាអំពីឧបករណ៍ទូទាត់សងប្រាក់នីមួយៗដែលបានទូទាត់សងក្នុងរយៈពេល ១០ ឆ្នាំ (ដប់ឆ្នាំ)

ច) បញ្ជីឈ្មោះ និងអាសយដ្ឋានចុងក្រោយបង្អស់របស់ភ្នាក់ងារខ្លួនទាំងអស់ និង

ឆ) កំណត់ត្រាផ្សេងៗទៀតដែលជាការតម្រូវរបស់ធនាគារជាតិនៃកម្ពុជា ។

២- ឯកសារដែលបានរៀបរាប់ក្នុងចំណុច១ អាចត្រូវបានរក្សាទុកក្នុងទម្រង់កំណត់ត្រាណាមួយក៏បាន ។

៣- កំណត់ត្រាទាំងអស់ដែលបានរក្សាទុកដោយអ្នកដំណើរការតតិយភាគី ដូចបានចែងក្នុងចំណុច១និង២ ត្រូវបានបើកចំហសម្រាប់ការធ្វើអធិការកិច្ចដោយធនាគារជាតិនៃកម្ពុជា អនុលោមតាមប្រការ ១៣ ។

៤- អ្នកដំណើរការតតិយភាគីត្រូវបំពេញកាតព្វកិច្ចដែលកំណត់ដោយច្បាប់ ឬបទបញ្ញាផ្សេងៗទៀត។

**ប្រការ១៨.-**

១- អ្នកដំណើរការតតិយភាគីត្រូវតំកល់ទុកជាមួយនឹងអាជ្ញាធរដែលត្រូវបានតែងតាំងដោយច្បាប់ នូវកំណត់ត្រាទាំងអស់ដែលបានតម្រូវតាមរយៈការរាយការណ៍អំពីរូបិយវត្ថុ ការរក្សាកំណត់ត្រា និងការរាយការណ៍អំពីប្រតិបត្តិការសង្ស័យ ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ អ្នកដំណើរការតតិយភាគីត្រូវដាក់កំណត់ចំពោះភ្នាក់ងារប្រតិស្រុតរបស់ខ្លួនអំពីការប្រមូលព័ត៌មានដែលគួរឱ្យជឿបានទាំងអស់ ដែលអាជ្ញាធរបានកំណត់សម្រាប់គោលបំណងនេះ ។

២- ការតំកល់ទុកទាន់ពេលនូវរបាយការណ៍ពេញលេញ និងត្រឹមត្រូវជាមួយអាជ្ញាធរសមស្រប គឺជាការគោរពតាមកាតព្វកិច្ចនៅក្នុងចំណុច១ ។

**ប្រការ ១៩.-**

១- លើកលែងតែមានចែងខុសពីក្នុងចំណុច២ ព័ត៌មាន ឬរបាយការណ៍ទាំងអស់ដែលធនាគារជាតិនៃកម្ពុជាបានទទួលពីអ្នកដំណើរការតតិយភាគី និងព័ត៌មានទាំងអស់ដែលមាននៅក្នុង ឬទាក់ទងនឹងរបាយការណ៍ត្រួតពិនិត្យ ស៊ើបអង្កេត ប្រតិបត្តិការ ឬស្ថានភាពដែលរៀបចំដោយ ឬសម្រាប់ការប្រើប្រាស់របស់ធនាគារជាតិនៃកម្ពុជា ឬរបាយការណ៍ហិរញ្ញវត្ថុ តារាងតុល្យការ គឺជាការសម្ងាត់ និងមិនត្រូវបានបើកចំហជាសាធារណៈឡើយ ។

២- ធនាគារជាតិនៃកម្ពុជាអាចបើកចំហព័ត៌មានដែលមិនមែនជាកម្មវត្ថុនៃការបើកចំហក្រោមចំណុច១ទៅឱ្យតំណាងភ្នាក់ងាររបស់រដ្ឋាភិបាល ដែលសន្យាជាលាយលក្ខណ៍អក្សរថានឹងរក្សាការសម្ងាត់នៃព័ត៌មានទាំងនោះ ឬធនាគារជាតិនៃកម្ពុជាយល់ឃើញថា ការផ្សព្វផ្សាយព័ត៌មានទាំងនោះ គឺជាការចាំបាច់សមស្របសម្រាប់ការពារសាធារណជន និងដើម្បីភាពយុត្តិធម៌ ហើយធនាគារជាតិនៃកម្ពុជាក៏បានជូនដំណឹងជាមុនដល់អ្នកដំណើរការតតិយភាគីអំពីគោលបំណងផ្សព្វផ្សាយព័ត៌មានទាំងនោះ ។

៣- ប្រការនេះមិនហាមឃាត់ធនាគារជាតិនៃកម្ពុជាចំពោះការបើកចំហដល់សាធារណជន អំពីបញ្ជីរាយនាមបុគ្គលដែលបានទទួលអាជ្ញាប័ណ្ណក្រោមប្រកាសនេះ ឬទិន្នន័យហិរញ្ញវត្ថុសរុប ដែលពាក់ព័ន្ធនឹងអ្នកដំណើរការតតិយភាគី និងភ្នាក់ងារប្រតិស្រុតរបស់អ្នកដំណើរការតតិយភាគី ឡើយ ។

## ជំពូក ៨
## នីតិវិធីរដ្ឋបាល

**ប្រការ ២០.-**

១- ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណរបស់អ្នកដំណើរការតតិយភាគី ឬ ចេញបញ្ជាដល់អ្នកដំណើរការតតិយភាគីឱ្យដកហូតការតែងតាំងភ្នាក់ងារ ប្រសិនបើ ៖

ក) អ្នកដំណើរការតតិយភាគីល្មើសនឹងប្រកាសនេះ ឬវិធានដែលបានអនុម័ត ឬបញ្ជា ឬសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលបានចេញផ្សាយក្រោមប្រកាសនេះ

ខ) អ្នកដំណើរការតតិយភាគីមិនសហការជាមួយធនាគារជាតិនៃកម្ពុជាក្នុងការត្រួតពិនិត្យ ឬការស៊ើបអង្កេត

គ) អ្នកដំណើរការតតិយភាគីបានប្រព្រឹត្តការក្លែងបន្លំ ធ្វើការបំភ័ន្តដោយចេតនា ឬមាន ការធ្វេសប្រហែសធ្ងន់ធ្ងរ

ឃ) ភ្នាក់ងារត្រូវបានផ្តន្ទាទោសចំពោះការប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការប្រឆាំងការ សំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬល្មើសនឹងវិធានដែលបានអនុម័ត ឬបញ្ជា ដែលបានចេញក្រោមប្រកាសនេះ

ង) អ្នកដំណើរការតតិយភាគីប្រព្រឹត្តទង្វើគ្មានសុវត្ថិភាព ឬមិនត្រឹមត្រូវ

ច) អ្នកដំណើរការតតិយភាគីមានអសាធនភាព ផ្អាកការទូទាត់សងបំណុលរបស់ខ្លួន ឬ ធ្វើការផ្ទេរសិទ្ធិទូទៅសម្រាប់ផលប្រយោជន៍ឥណទាយករបស់ខ្លួន ឬ

ឆ) អ្នកដំណើរការតតិយភាគីមិនដកភ្នាក់ងារចេញតាមបញ្ជាជាចុងក្រោយរបស់ធនាគារ ជាតិនៃកម្ពុជា រួមទាំងការរកឃើញថាភ្នាក់ងារបានប្រព្រឹត្តល្មើសនឹងប្រកាសនេះផង ។

២- ដើម្បីកំណត់ថា អ្នកដំណើរការតតិយភាគីបានប្រព្រឹត្តទង្វើគ្មានសុវត្ថិភាព ឬមិនត្រឹមត្រូវ ធនាគារជាតិនៃកម្ពុជាអាចពិចារណាទៅលើទំហំ និងលក្ខខណ្ឌនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់ ទំហំនៃការខាតបង់ ភាពធ្ងន់ធ្ងរនៃបទល្មើស និងការប្រព្រឹត្តពីមុនរបស់បុគ្គលពាក់ព័ន្ធ ។

**ប្រការ ២១.-**

ប្រសិនបើធនាគារជាតិនៃកម្ពុជាពិនិត្យឃើញថា ការប្រព្រឹត្តល្មើសរបស់អ្នកដំណើរការតតិយភាគីចំពោះប្រកាសនេះ ឬវិធានដែលបានអនុម័តិ ឬបញ្ជា ឬសេចក្តីបង្គាប់ ឬសេចក្តីណែនាំ ដែលបានចេញផ្សាយក្រោមប្រកាសនេះអាចនឹងធ្វើឱ្យអ្នកដំណើរការតតិយភាគី អតិថិជនរបស់អ្នកដំណើរការតតិយភាគី ឬសាធារណជនទទួលមហន្តរាយភ្លាមៗ និងមិនអាចស្តារឡើងវិញបាន ឬបណ្តាលឱ្យមានអសាធនភាព ឬធ្វើឱ្យបាត់បង់ទ្រព្យសកម្មរបស់អ្នកដំណើរការតតិយភាគី ធនាគារជាតិនៃកម្ពុជាអាចចេញបញ្ជាតម្រូវឱ្យអ្នកដំណើរការតតិយភាគីបញ្ឈប់សកម្មភាពល្មើសនោះភ្លាម ។

**ប្រការ ២២.-**

ធនាគារជាតិនៃកម្ពុជាអាចដាក់ពិន័យចំពោះបុគ្គលដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ឬវិធានដែលបានអនុម័តិ ឬបញ្ជាដែលបានចេញក្រោមប្រកាសនេះ ក្នុងចំនួនប្រាក់ ១០០.០០០រៀល (មួយរយពាន់រៀល) ក្នុងមួយថ្ងៃទៅតាមចំនួនថ្ងៃនៃការប្រព្រឹត្តល្មើស ។

**ប្រការ ២៣.-**

១- គ្មានបុគ្គលណាមួយអាចធ្វើរបាយការណ៍ក្លែងបន្លំ បំភ័ន្ត ឬធ្វើលិខិតបញ្ជាក់ក្លែងក្លាយដោយចេតនានៅក្នុងកំណត់ត្រាដែលបានដាក់ជូន ឬដែលបានតម្រូវឱ្យរក្សាទុកក្រោមប្រកាសនេះ ឬមានចេតនាធ្វើកំណត់ត្រាក្លែងក្លាយ ឬលុបចោលការកត់ត្រាសំខាន់ៗនៅក្នុងរបាយការណ៍នោះឡើយ ។

២- គ្មានបុគ្គលណាមួយ អាចធ្វើសកម្មភាពដោយចេតនានៅក្នុងសកម្មភាពប្រតិបត្តិការទូទាត់សងប្រាក់ដោយពុំទាន់បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ ។

៣- ប្រសិនបើធនាគារជាតិនៃកម្ពុជាមានមូលហេតុច្បាស់ថា បុគ្គលណាបាន ឬកំពុងប្រព្រឹត្តល្មើសនឹងប្រការ ៣ នៃប្រកាសនេះ ធនាគារជាតិនៃកម្ពុជាអាចចេញបញ្ជាដើម្បីបញ្ឈប់បុគ្គលនោះភ្លាម ។

## ជំពូក ៩
## អវសានប្បញ្ញត្តិ

**ប្រការ ២៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ២៥.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី២៥ ខែ សីហា ឆ្នាំ ២០១០

**ទេសាភិបាល**

**ជា-ចាន់តូ**

**កន្លែងទទួល**
- ដូចប្រការ ២៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**
- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B9-010-151 P.K

*Unofficial Translation*

# PRAKAS
# on
# Third-Party Processors

## The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13, dated November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Kram NS/RKM/1005/030, dated October 24, 2005 promulgating the Law on Negotiable Instruments and Payment Transactions;
- With reference to the Royal Kram NS/RKM/1206/036, dated December 29, 2006 promulgating the amendment of article 14 and 57 of the Law on the Organization and Conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/0607/014, dated June 24, 2007 promulgating the Law on Anti-Money Laundering and Combating the Financing of Terrorism;
- With reference to the Royal Degree NS/0508/526, dated May 13, 2008 on the appointment of His Excellency **Chea Chanto** as Governor of the National Bank of Cambodia, as equivalent to Senior Minister;
- Pursuant to the agreement reached at the meeting of the senior officials of the National Bank of Cambodia on August 17, 2010;

## DECIDES
## Chapter I
## General Provisions

**Article 1.-**

The purpose of this Prakas is to enable Banks as defined under the Law on Banking and Financial Institutions, hereafter referred to as "Bank", to outsource one or more parts of their payment transactions services through one or more third-party processors, as may be



P.O Box25, 22-24 Preah Norodom Blvd, Phnom Penh Cambodia Phone : 855 23 722563
Fax/Phone : 855 23 426117

agreed between the Bank and those third-party processors, and subject to prior approval from the National Bank of Cambodia (also "NBC"), in conformity with Article 204 of the Law on Negotiable Instruments and Payment Transactions.

**Article 2.-**

- **Third-party Processor** means a person entrusted by a Bank to conduct one or more parts of its payment transactions services.

- **Outsourcing** consists of a Bank entrusting by way of agreement a legal person or another Bank to provide one or more parts of its services on its behalf.

## Chapter II

## Payment Transactions Services

**Article 3.-**

1. A person which is not a Bank may not engage in the business of payment transactions or hold itself out as providing payment transactions services unless the person

a) is entrusted by agreement by a Bank to act as its Third-party-Processor, and

b) is licensed by the National Bank of Cambodia

2. Once entrusted by the Bank and licensed by NBC, a Third-party Processor may act on behalf of the Bank to provide one or more of the following services, as specified in Article 203 of Law on Negotiable Instruments and Payment Transactions:

(i) A communication facility

(ii) An inter-bank clearing facility, which may further transmit inter-bank settlement information to Banks, including the Bank in which settlement is completed;

(iii) Managing or operating of Bank customers' accounts; and/or

(iv) Play as a sending and receiving point for payment orders sent or received by the Bank, which may be accessed directly by the Bank's customers for sending and receiving payment orders and in addition:

(v) A service provider of money remittance by mobile phone or other means

(vi) A service provider of clearing and settlement of debit and credit card payment

**Article 4.-**

1. The Third-party Processor can also manage and operate on behalf of one or more Banks, a payment system for:

a) Payment transactions and cash withdrawals,

b) Clearing and settlement for instruments of domestic and foreign currency payment in Cambodia.

2. In this event, it shall be duly entrusted to provide such services by each and all Banks taking part into the payment system and respective liabilities shall be duly allocated.

**Article 5.-**

A Third-party Processor managing a Payment System shall be subject to existing NBC Prakas on Payment Clearing Systems, Prakas on Control of Systemic Risk of Payment Systems and Prakas on the Operation of Settlement Accounts, and any other relevant measure, as applicable.

## Chapter III

## Bank's Application for Licensing Third-Party Processor

**Article 6.-**

1. Before allowing a Third-party Processor to conduct any payment transactions services, the Bank shall apply for a license on behalf of such Third-party Processor, issued by the NBC. The application must state or contain as follows:

a) The legal name and residential and business addresses of the Third-party Processor and any fictitious or trade name used by such Third-party Processor in conducting its business on behalf of the Bank and a description of its legal status;

b) A description of payment transactions services previously provided by the Third-party Processor also inside and outside Cambodia, if any, and the payment transactions services that the Third-party Processor seeks to provide in Cambodia on behalf of the Bank;

c) A description of the legal means to be undertaken to protect the customers' funds from any risk coming from the outsourcing of the services, allocation of Anti-Money Laundering and Terrorism Financing, and Know-your-Customer duties, and measures to make and keep the customers aware of the role of the Third-party Processor into the payment transactions services..In case of use of Agents, their functions and legal status shall be described.

2. The application must be attached by the following documents:

- The decision of the concerned Bank management body to allow the Bank to provide one or more parts of their payment transactions services to a Third-party Processor.

- The agreement between the Bank and the Third-party Processor to provide and to accept the services.
- The authorization from the parent company or head office, as relevant, to allow their branch or subsidiary to act as Third-party Processor.
- A guarantee letter issued by the Bank that commits to undertake all responsibilities on the ongoing activities of the Third-party Processor.

3. An application fee of Riel 2,000,000 (Two millions Riel) must be accompanied with the application for a license.

4. The annual license fee of Riel 10,000,000 (Ten millions Riel) shall be paid by the Bank on behalf of Third-party processor by 15 January of each year.

5. For Banks applying for third-party license during the year, the license fee shall be calculated on pro rata basis for the period remaining to year's end.

6. In the event of late payment of the annual license fee, the Bank concerned shall be fined by paying interest on the overdue payment at the prevailing refinancing interest rate for a period up to thirty days.

**Article 7.-**

1. The license is valid for a period of three years, from the approval date. A license may be renewed only if the Third-party Processors' activities comply with laws and regulations and all infractions of relevant laws and prudential regulations, if any, have been remedied.

2. An application for renewal of a license shall be submitted to the National Bank of Cambodia at least three months before the expiration of the existing license. In the event that the request includes new services or substantially different methods to provide the same services, the NBC shall consider this as a request for a new license.

3. In the event this deadline is not met, a fine of Riel 1,000,000 (One million Riel) per day of delay up to the submission date shall be imposed.

4. Bank, which would remain not compliant beyond this period or any extension of time granted by the NBC, would be subject to a suspension of Third-party Processor's license. The suspension shall be lifted if, within 20 (Twenty) days after its license is suspended, the Bank:

a) Submits the application for renewal and pays the renewal fee to Third-party Processor; and

b) Pays Riel 200,000 (Two hundreds thousand Riel) for each day after suspension.

5. If a Bank would remain not fulfilled section 4 above, that Bank would be subject to a more serious penalty, which could go up to the revocation of Third-party Processor's license.

**Article 8.-**

1. The NBC shall approve or deny the application within 30 days (Thirty days) after the application date.

2. The NBC may for good cause extend the application period.

3. The license shall clearly state for what services or activities this is issued and/or subject the license to restrictions in the scope or means to provide such services.

4. The NBC can ask the Bank and the Third-party Processor to modify parts of the agreements to be undertaken should these results in excessive risk for the national payments system or the market.

**Article 9.-**

1. A Bank that entrusts one or more parts of payment transactions services to a Third-party Processor shall applies for renewal license not later than 30 days (Thirty days) before the expiration of the existing license. Bank must fulfill its obligation in giving information and pay the renewal license fee on behalf of the Third-party Processor.

2. The renewal application must contain:

   a) a copy of the Bank's most recent audited annual financial statement.

   b) description of each material change in information of its Third-party Processor in its original license application which has not been reported to the NBC on any required report;

   c) a list of the locations in Cambodia where its Third-party Processor engages in payment transactions or provides other payment transactions services;

   d) indication of any serious complaint or legal action undertaken by customers or third parties in relation of the licensed services.

## Chapter IV

## Duties and Responsibilities of the Bank

**Article 10.-**

Bank that received a license for Third-party Processor must act as follows:

1. Be fully responsible for any action or omission of the Third-party Processor and agent acting under its authority and on its behalf.

2. Ensure that a Third-party Processor operates under its full control and supervision in matters in which it acts on its behalf in order to ensure its compliance with this Prakas and with all other legal requirements. The Bank is precluded from denying such control and supervision.

3. Ensure that the Third-party Processors acting on its behalf and their Authorised Agents inform customers of this fact.

4. Ensure that the Third-party Processors Services have appropriate operational and technical safety and security to provide:

i) unique service event records and audit trails,

i) "per event" and "per customer" confirmations, investigation and reporting,

ii) reliable detection and rejection of failed or fraudulent service events

iv) tamperproof retention and storage of historical records

**Article 11.-**

The relationship and obligations of the Bank towards its clients shall not be materially altered by the outsourcing of any activities under this Prakas

## Chapter V

## Duties and Responsibilities of Third-Party Processor

**Article 12.-**

Third-party Processor acting payment transaction on behalf of bank shall have the following duties:

1. Select one or more agents to facilitate cash-in and cash-out transactions.

2. Shall have a legal binding contract with its selected agent and shall define clearly its policies and procedures for its agent to be fully complied with.

3. Ensure that its selected agent shall not provide payment transactions services outside the scope of activity permissible under the agency agreement between the Agent and the Third-party Processor.

4. Ensure that the services provided by itself or any appointed agent have appropriate operational and technical safety and security to provide:

i) unique service event records and audit trails,

i) "per event" and "per customer" confirmations, investigation and reporting,

ii) reliable detection and rejection of failed or fraudulent service events

iv) tamperproof retention and storage of historical records

**Article 13.-**

A Third-party Processor has to be fully responsible for all its actions including its selected agent as follows:

1. Be fully responsible for any action or omission of an Authorised Agent providing payment transactions services on its behalf both against any third parties and the Bank.

2. Ensure that its Agents operate under its full control and supervision in matters in which it acts on its behalf. The Third-party Processor is precluded from denying such control and supervision.

3. Shall provide to NBC on a monthly basis, certified by the concerned Bank, the list of Agents together with their name and address of the location where they provide their services.

## Chapter VI

## Account Management

**Article 14.-**

A Bank that entrusts of transferring transactions services to a Third-party Processor shall require a Third-party Processor to open an account in its own bank in order to hold cash that has received from customers for transferring purpose such as through mobile phones.

This Third-party Processor's account is in the form of Trust Account, which is only used to transfer customer's transaction and is not used in any other purposes.

The respective bank has duties to monitor this account regularly and in the case of Third-party Processor cease of service providing or bankruptcy, bank must retain this account in order to protect customer's benefits. The balance of this account is not the property of the Third-party processor.

## Chapter VII

## Examinations, Reports and Records

**Article 15.-**

1. The NBC may conduct an annual examination of a Third-party Processor or if necessary a Bank upon 30 (Thirty) days' notice in a record.

2. The NBC may examine a Third-party Processor at any time, without notice, if the NBC has reasons to believe that the Third-party Processor is engaging in an unsafe or unsound practice or has violated or is violating this Prakas or an order issued under this Prakas.

3. If the NBC concludes that an on-site examination is necessary under paragraph (1) and (2) above, the Third-party Processor or the Bank shall pay the reasonable cost of the examination.

4. Information obtained during an examination under this Prakas may be disclosed only as provided in Article 17.

**Article 16.-**

1. A Third-party Processor shall file with the NBC within 15 (Fifteen) business days any material changes in information provided in the application as prescribed by the NBC.

2. With the certification of the Bank concerned, a Third-party Processor shall file with the NBC within 30 days (Thirty days) after the end of each fiscal quarter

a) a year-to-date financial statements of the payment transactions, including a balance sheet and statement of income and expenses;

b) payment transactions activity including monthly summaries of its activities for each month, broken down to categories as directed by the Bank concerned.

c) a list of all services currently offered by the Third-party Processor and the days and hours of the operation of the payment transactions services;

d) any other information required by the NBC.

**Article 17.-**

1. A Third-party Processor shall maintain for at least 10 (ten) years a log or logs of its activities containing for each transaction information and particularly the following records for determining the Third-party Processor's compliance with this Prakas:

a) a record of each payment instrument;

b) a general ledger posted at least monthly containing all asset, liability, capital, income, and expense accounts;

c) bank statements and bank reconciliation records;

d) records of outstanding payment instruments;

e) records of each payment instrument paid within the 10 (ten)-year period;

f) a list of the last known names and addresses of all of its Agents; and

g) any other records required by the NBC.

2. The items specified in paragraph (1) may be maintained in any form of record.

3. All records maintained by the Third-party Processor as required in paragraph (1) through (2) are open to inspection by the NBC pursuant to Article 13.

4. The Third-party Processor shall fulfil requirements imposed by other laws or regulations.

**Article 18.-**

1. A Third-party Processor shall file with the authority designated by law all reports required by currency reporting, record keeping, and suspicious transaction reporting requirements as set forth in the Law on Anti-Money Laundering and Combating the Financing of Terrorism. It shall impose to its Authorized Agents the collection of all relevant information imposed by such authority for such purposes.

2. The timely filing of a complete and accurate report with the appropriate authority is compliance with the requirements of paragraph (1).

**Article 19.-**

1. Except as otherwise provided in paragraph (2), all information or reports obtained by the NBC from the Third-party Processor, and all information contained in or related to examination, investigation, operating, or condition reports prepared by, or for the use of the NBC, or financial statements, balance sheets, are confidential and are not subject to disclosure.

2. The NBC may disclose information not otherwise subject to disclosure under paragraph (1) to representatives of the Government who undertake in a record that they will maintain the confidentiality of the information; or the NBC finds that the release is reasonably necessary for the protection of the public and in the interests of justice, and the Third-party Processor has been given previous notice by the NBC of its intent to release the information.

3. This article does not prohibit the NBC from disclosing to the public a list of persons licensed under this Prakas or the aggregated financial data concerning those Third-party Processors and their Authorised Agents.

## Chapter VIII

## Administrative Procedures

**Article 20.-**

1. The NBC may suspend or revoke a license of a Third-party Processor, or order a Third-party Processor to revoke the designation of an Agent if:

a) the Third-party Processor violates this Prakas or a rule adopted or an order, directive or instruction issued under this Prakas;

b) the Third-party Processor does not cooperate with an examination or investigation by the NBC;

c) the Third-party Processor engages in fraud, intentional misrepresentation, or gross negligence;

d) an Agent is convicted of a violation of the Law on Anti-Money Laundering and Combating the Financing of Terrorism, or violates a rule adopted or an order issued under this Prakas;

e) the Third-party Processor engages in an unsafe or unsound practice;

f) the Third-party Processor is insolvent, suspends payment of its obligations, or makes a general assignment for the benefit of its creditors; or

g) the Third-party Processor does not remove an Agent after the NBC issues a final order including a finding that the Agent has violated this Prakas.

In determining whether a Third-party Processor is engaging in an unsafe or unsound practice, the NBC may consider the size and condition of the Third-party Processor's payment transactions services, the magnitude of the loss, the gravity of the violation, and the previous conduct of the person involved.

**Article 21.-**

If the NBC determines that a violation of this Prakas or a rule adopted or an order, directive or instruction issued under this Prakas by the Third-party Processor is likely to cause immediate and irreparable harm to the Third-party Processor, its customers, or the public, or cause insolvency or significant dissipation of assets of the Third-party Processor, the NBC may issue an order requiring the Third-party Processor to cease and desist from the violation.

**Article 22.-**

The NBC may assess a civil penalty against a person that violates this Prakas or a rule adopted or an order issued under this Prakas in an amount of KHR 100,000 per day for each day the violation is outstanding.

**Article 23.-**

1. No person shall intentionally make a false statement, misrepresentation, or false certification in a record filed or required to be maintained under this Prakas or shall intentionally make a false entry or omit a material entry in such a record.

2. No person shall knowingly engage in the payment transactions activity without obtaining a license from National Bank of Cambodia.

3. If the NBC has reason to believe that a person has violated or is violating Article 3 of this Prakas, the NBC may issue an order to cease and desist that person.

## Chapter IX

## Final Provisions

**Article 24.-**

The General Director, the General Secretariat, the General Inspection, the General Cashier and all Departments of the National Bank of Cambodia, entities and all Banking and Financial Institutions under the NBC's supervisory authority shall strictly implement this Prakas.

**Article 25.-**

This Prakas shall have effect from the signing date.

Phnom Penh, August 25, 2010

**The Governor**

Signed and Sealed: **CHEA CHANTO**

CC: - The parties concerned as stated in Article 24

- The member of the Board of directors
- File
- CM for info
- Administration Department of CM
- for publication in the National Gazette

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ...១៩៨... ឧ.ក.ថ-ក.ក.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ៣ ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ១៥១/១០ គ.វ.ក ចុះថ្ងៃទី២២.០១.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ខេមបូឌាន ហុងកុង ហ្គោលដេន អាត អ៊ិនដាសស្ទ្រៀល ចុះថ្ងៃទី៣១.១២.២០០៩

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌាន ហុងកុង ហ្គោលដេន អាត អ៊ិនដាសស្ទ្រៀល តំណាងដោយ លោក DENG XIAOQING សញ្ជាតិចិន (ហុងកុង) អាយុ៥៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G35921133 ចុះថ្ងៃទី១០.០៦.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ New Tech Plaza 34, Tai Yau Street San Po Kong Kin, Hong Kong ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល |
|---|---|
| ផ្កាសិប្បនិម្មិត | ៣៥៦០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣

-ផ្លាកឈ្មោះរោងចក្រ ៖ " *ខេមបូឌាន ហុងកុង ហ្គោលដេន អាត អ៊ិនដាសស្ទ្រៀល* ***(CAMBODIAN HONG KONG GOLDEN ART INDUSTRIAL CO.,LTD.)*** "

-ទីតាំងរោងចក្រ ៖ " *ផ្លូវចោមចៅ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ* "

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្មដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។/.

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបានអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៥:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនព្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ